ប្រលោមលោកផ្នែកមនោសញ្ចេតនា លំនាំរឿងពិត

# ក្រោមតំណក់ទឹកភ្លៀង

និពន្ធដោយ

**អ្នកស្រី អ៊ុំ សុផានី**

រង្វាន់លេខ៣ "មេដាយសំរិទ្ធិ"
ផ្តល់ដោយក្រសួងឃោសនាការ និងវប្បធម៌
ក្នុងឱកាសបុណ្យជាតិ ៧ មករា ឆ្នាំ ១៩៨៩ ខួបលើកទី១០
ប្រារព្ធធ្វើពិធីចែករង្វាន់នៅថ្ងៃ ៤ មេសា ១៩៨៩

**គ្រឹះស្ថានបោះពុម្ពផ្សាយ បឹងទន្លេសាប**
BOENG TONLE SAP PUBLISHER

## *អារម្ភកថា*

សូមឧទ្ទិសដល់វិញ្ញាណក្ខ័ន្ធយុវជនតំបន់ឥណ្ឌូចិន ដែលបានពលីដើម្បីបុព្វហេតុបដិវត្តន៍ និងជនស្លូតត្រង់ទាំងឡាយដែលបានចែកឋានទៅ ដោយដក់ជាប់នូវការរងអំពើទារុណកម្មគ្រប់បែបយ៉ាងដោយអយុត្តិធម៌។ ថ្វីត្បិតតែរឿង "ក្រោមតំណក់ទឹកភ្លៀង" ពុំអាចបកស្រាយឲ្យបានក្បោះក្បាយ ល្អិតល្អន់ នូវបទឧក្រិដ្ឋរាប់លានប្រការក៏ដោយ ក៏ជាការរួមចំណែកលាតត្រដាង បកស្រាយ ឆ្លុះបញ្ចាំងពីសង្គមព្រៃផ្សៃ ឃោរឃៅ ឥតព្រំដែន ដែលគេនឹកស្មានតែមាននៅក្នុងរឿងព្រេងនិទានតែប៉ុណ្ណោះ។ ប៉ុន្តែការពិតជាក់ស្តែង គឺមាន...ថ្មីៗ...ក្នុងសតវត្សរ៍ទី ២០ លើទឹកដីកម្ពុជា តំបន់អាស៊ីភាគអាគ្នេយ៍នេះឯង។

តើមានប្រជាជនណា ដែលឋិតនៅក្រោមតំណក់ទឹកភ្លៀងហើយ មិនទទឹកទឹកភ្លៀង ?

តើមានប្រជាជនណា ដែលឋិតនៅក្នុងរបបប្រល័យពូជសាសន៍របស់ ប៉ុល ពត ហើយមិនជួបប្រទះការនិរាសព្រាត់ប្រាស់គ្រួសារ ?

សូមឧទ្ទិសដល់វិញ្ញាណក្ខ័ន្ធបងស្រីសម្លាញ់ សូមឲ្យអ្នកឋិតនៅក្នុងសុគតិភព ដោយស្ងប់ចុះ ព្រោះប្អូនស្រីរបស់អ្នកបានសងគុណអ្នកហើយ ដោយការចងក្រងភស្តុតាងទុកជាឯកសារអមតៈ។

*អ្នកស្រី អ៊ុំ សុផានី*

# ១. ស្រមោលអតីតកាល

បុណ្យប្រពៃណីជាតិ (ចូលឆ្នាំខ្មែរ) និងបុណ្យជ័យជម្នះដប់ប្រាំពីរ មេសា (១៧ មេសា) បានកន្លងផុតទៅថ្មីៗសើមៗ ទាំងមិនទាន់រលុបពីអារម្មណ៍របស់ខ្មែរគ្រប់ៗរូបផង គេនៅតែនឹកពីសេចក្ដីសប្បាយរីករាយផងទាំងពួង ដែលខ្លួនគេម្នាក់ៗបានចូលរួមយ៉ាងសស្រាក់សស្រាំ។ ចំណែកឯបក្ស និងរដ្ឋក៏បានបង្កលក្ខណៈឲ្យមានល្បែងប្រជាប្រិយគ្រប់ប្រភេទ...បង្កើតកន្លែងកម្សាន្តនានាគ្រប់ទីកន្លែង ពាសពេញលើផ្ទៃប្រទេសកម្ពុជា។ ឱ! អីក៏សប្បាយរីករាយអ្វីម្ល៉េះទេ ទោះបីឆ្នាំនេះជាឆ្នាំគម្រប់លើកទី៦ នៃពិធីប្រារព្ធធ្វើបុណ្យចូលឆ្នាំក៏ដោយ ក៏ខ្ញុំនៅតែទទួលសេចក្ដីសប្បាយរីករាយពុំមានជិនណាយសោះ។ រីឯក្ដីក្ដុកក្ដួល នឹកសង្វេគ អនិច្ចាដល់យុវជន និងញាតិមិត្តជិតឆ្ងាយដែលបានចែកឋានទៅដោយបិទភ្នែកមិនជិត ព្រោះត្បិតសេចក្ដីប៉ងប្រាថ្នាទាំងឡាយរបស់គេនៅមិនទាន់បានសម្រេចនៅឡើយ។ ប៉ុន្តែធ្វើដូចម្ដេចទៅហ្ន៎ នឹងនិយាយប្រាប់ទៅយុវជនទាំងឡាយ ដែលបានពលីសាច់ស្រស់ឈាមស្រស់ ព្រោះតែបុព្វហេតុបដិវត្ត ដែលឥឡូវនេះ គេកំពុងសម្រាកជាអចិន្ត្រៃយ៍ក្នុងព្រះធរណីឲ្យបានដឹងថា : "ពន្លឺសន្តិភាពដែលបានមកពីការខំប្រឹងប្រែង រហូតដល់តំណក់ឈាមចុងក្រោយរបស់គេ បានលេចចេញជារូបរាងពិតប្រាកដហើយ" តែណ្ហើយចុះ ទោះបីគេពុំបានដឹងពីសភាពការណ៍ បន្ទាប់ពីគេបានបាត់បង់ជីវិតទៅ

ហើយក៏ដោយ ក៏ព្រលឹងរបស់ពួកគេនៅតែទទូចជានិច្ច សូមឲ្យអ្នកបន្តវេនទាំងឡាយ មេត្តាជួយនាំគ្នាពន្លត់ភ្លើងសង្គ្រាមឲ្យរលត់ជាស្ថាពរ ហើយសំណូមពរតែមួយគត់គឺ សូមកុំឲ្យមានគ្រាប់ផ្លោង ឬគ្រាប់រំសេវឯណាមកបន្លឺសូរស័ព្ទញ័ររន្ធត់នៅលើទឹកដី ដែលជាការរំខានដល់ពួកគេ ដែលកំពុងតែសម្រាកនាពេលអវសាននេះទៀត។ តើអ្នកដែលមានជីវិតរស់នៅទាំងឡាយ ហ៊ានទទួលភារកិច្ចបន្តវេនពន្លត់ភ្លើងសង្គ្រាមនេះទេ?

នឹកដល់ត្រង់នេះ... ទឹកភ្នែកថ្លាដូចគ្រាប់ពេជ្រច្នៃពីរតំណក់... ក្តៅឧណ្ហៗហូរកាត់ថ្ពាល់ទាំងគូ រួចស្រក់ធ្លាក់ចុះលើសម្លៀកបំពាក់ ដែលខ្ញុំកំពុងតែរៀបចំដាក់ក្នុងកូនសំពៀតស្បែកតូចមួយយ៉ាងផ្ចិតផ្ចង់។ ខ្ញុំរូតខ្សែរូតបិទភ្ជិតកូនសំពៀតស្បែក... ពេលនោះឮសូរស្នូរគោះទ្វារ ខ្ញុំក៏ងើបដើរទៅបើកទ្វារដែលមិនទាន់ដាក់គន្លឹះ ចាក់សោមាំទាំនៅឡើយ លេចស្រីចំណាស់ម្នាក់ស្លៀកសារុងពុម្ពផ្កាពណ៌សូកូឡាក្រមៅពាក់អាវស កស្រួចវាលក្លៀក... ជីបរាងទាំងមុខទាំងក្រោយ ព្រមទាំងមានដាក់ហោប៉ៅពីរនៅខាងមុខទៀតផង។ ស្រីចំណាស់ហើបមាត់ឡើង បំណងនឹងនិយាយឆ្លើយឆ្លង បង្ហាញឲ្យឃើញធ្មេញស្រោបមាសពណ៌រមៀតស្អុយ លេចចាំងនឹងរន្ទះពន្លឺភ្លើងអគ្គិសនីព្រាកៗ ៖

- ឯងមិនទាន់ដេកទេឬ? មីអូន!

ទោះបីស្រីចំណាស់ហៅមិនចំឈ្មោះខ្ញុំ ក៏ខ្ញុំងើបមុខនិយាយតបទៅវិញ ទាំងទឹកមុខធម្មតា ៖

- ចាំមីង... បែបនេះ ខ្ញុំដូចជាមិនងងុយគេងសោះ។

ស្រីចំណាស់ឈ្មោះ "ម៉ៅ" បន្តសម្តី ដោយបង្ហួសដំណើរមកអង្គុយចុះនៅលើ





ក្តារជឿខាងក្នុង ៖

- ប្រញាប់សម្រាកទៅក្មួយ ព្រោះស្អែកឯងត្រូវធ្វើដំណើរ...

មីងម៉ៅឈប់បន្តិច ហាក់ដូចជាគិតគូរបូកប៉ាន់ចម្ងាយផ្លូវ ហើយលាន់មាត់ ៖

- យី... ផ្លូវឆ្ងាយណាស់!

និយាយចប់ ស្រីចំណាស់ក៏ហុចកូនកំប៉ុងសភ្លឹងមួយមកឲ្យខ្ញុំ (កំប៉ុងនេះជាកំប៉ុងដាក់ម្សៅទឹកដោះគោកូនក្មេងយីហោ ហ្គីហ្គោ ប៉ុន្តែ វារបកក្រដាសផ្លាកអស់ហើយ) ដៃហុច មាត់និយាយ ៖

- មីងធ្វើត្រីផាត់បានមួយកំប៉ុងនេះឲ្យឯង។

ខ្ញុំទទួលយកកំប៉ុង ដោយមិនភ្លេចឆ្លើយតបជាពាក្យគួរសម ៖

- ក្មួយអរគុណណាស់មីង។

បន្ទាប់មក មីងលូកហោប៉ៅអាវដកយកក្រដាសប្រាក់ចំនួន ២០០ រៀល ហុចបន្ថែមមកឲ្យខ្ញុំទៀត។ ខ្ញុំមានអាកប្បកិរិយាស្ទាក់ស្ទើរ រហូតទាល់តែមីងបង្ខំ ទើបខ្ញុំលូកដៃទទួល លើកនេះខ្ញុំមិនថ្លែងអំណរគុណ ដូចពេលទទួលកំប៉ុងត្រីផាត់ទេ ប៉ុន្តែ ខ្ញុំបែរជានិយាយ ៖

- មីងល្អនឹងខ្ញុំណាស់... ខ្ញុំមិនដឹងជាបានអ្វីតបស្នងសងគុណមីងឲ្យ...

មីងម៉ៅឆ្លើយកាត់ពាក្យខ្ញុំ រកតែខ្ញុំបញ្ចប់មិនទាន់។

- គុណស្រាយអីប៉ុណ្ណឹង... នេះជាករណីយកិច្ចរបស់មនុស្ស ដែលត្រូវតែចេះជួយធុរៈគ្នាក្នុងពេលគ្រាក្រដូច្នេះឯង។

ថាហើយ មីងម៉ៅក៏ងើបពីក្តារជឿ ហើយនិយាយតឿនខ្ញុំសាជាថ្មីម្តងទៀត ព្រមទាំងបោះជំហានមួយៗសំដៅទ្វារ ៖

- សម្រាកទៅណា ក្មួយណា។

ខ្ញុំដើរតាមក្រោយមីងម៉ៅ ដោយឥតនិយាយស្តីអ្វីឡើយ។ ពេលមីងម៉ៅចេញផុតទៅ ខ្ញុំក៏ទាញទ្វារបិទដាក់គន្លឹះចាក់សោ រួចក៏ដើរត្រឡប់មកយកកំប៉ុង និងក្រដាសប្រាក់ ២០០ រៀល ដែលមីងម៉ៅទើបតែប្រគល់ឲ្យមកខ្ញុំមុននេះបន្តិច ដាក់បន្ថែមទៅក្នុងកូនសំពៀតស្បែក។ ទោះបីជាមានរបស់បន្ថែមប៉ុណ្ណោះក៏ដោយ ក៏មិនធ្វើឲ្យកូនសំពៀតរបស់ខ្ញុំចង្អៀតដែរ។ រៀបចំរួចរាល់ហើយ ខ្ញុំក៏ដើរទៅបិទភ្លើងទាំងអស់ ទុកនៅតែកូនអំពូលតូចមួយ គ្រាន់តែឲ្យមានពន្លឺព្រាលៗ ដើម្បីកុំឲ្យងងឹតខ្លាំងពេក។ ខ្ញុំឡើងទៅប្រះខ្លួនសម្រាកលើគ្រែ ដែលមានក្បាច់រចនាបៀបបុរាណធ្វើអំពីឈើក្រញូងពណ៌ក្រមៅរលោងស្រិល ប៉ុន្តែបំពេញបន្ថែមដោយរនូតធ្វើពីឫស្សីពីងពង់ ក្រាលកន្ទេលលើកគោម នៅចំកណ្តាលមានត្បាញជារូបប្រាសាទអង្គរវត្តព្រមទាំងមានចំជុំវិញជាយកន្ទេលដោយក្រណាត់ជតី (ក្រណាត់ទេសឯកពណ៌ក្រហម ដែលអ្នកស្រុកនិយមហៅ ជតី ដូច្នេះ) ទៀតផង... ខ្ញុំទាញមុងទម្លាក់ ហើយបិទភ្នែកបំណងឲ្យលក់ភ្លាម ប៉ុន្តែភ្នែកខ្ញុំបិទមិនជិតសោះ ហាក់ដូចជាមានអ្វីមកខ្ទាស់ ធ្វើឲ្យអារម្មណ៍គិតវែងឆ្ងាយ... រាយមាយ... រសាប់រសល់... ប្រែប្រួលចុះឡើងម្តងបែរទៅឆ្វេង... ម្តងបែរទៅស្តាំ... ខ្ញុំដឹងថា ប្រហែលជាពាក់កណ្តាលអធ្រាត្រទើបខ្ញុំនិទ្រាលង់លក់។ នៅខាងក្រៅ ស្នូរខ្យល់បក់ផាយផាត់ប៉ះនឹងស្លឹករុក្ខជាតិនានា លាន់សូរស័ព្ទជួនតិចជួនខ្លាំង ហាក់ដូចជាតូរ្យតន្ត្រីដែលគេកំពុងតែប្រគំរងំយ៉ាងពីរោះរណ្តំណែងណង នាពេលរាត្រីស្ងាត់។

◆ ◆ ◆

ខ្ញុំភ្ញាក់ពីព្រលឹមស្រាងៗ លុបលាងខ្លួនប្រាណ រួចស្លៀកពាក់យ៉ាងសមរម្យ





លើកសំពៀតដែលបានរៀបចំរួចតាំងពីយប់មកស្ពាយលើស្មា ទាញទ្វារបិទដាក់គន្លឹះចាក់សោយ៉ាងត្រឹមត្រូវ ហើយឆ្លៀតទៅជម្រាបលាមីងម៉ៅ និងអ្នកជិតខាងព្រមទាំងផ្តាំផ្ញើឲ្យគេជួយមើលផ្ទះសម្បែងឲ្យខ្លួនផង។ ខ្ញុំធ្វើដំណើរដោយជើងទៅកន្លែងដែលប្រធានក្រុមណាត់ឲ្យមកជួបជុំគ្នា ដើម្បីឡើងឡាន។ ទៅដល់ទីណាត់ជួបគ្នា ខ្ញុំឃើញវត្តមានសមមិត្តខ្លះបានមកដល់មុនខ្ញុំទៅទៀត គេអង្គុយរង់ចាំគ្នីគ្នាក្បែរកាបូបស្ពាយ មានសម្លៀកបំពាក់ជាអ្នកធ្វើដំណើរ។ ខ្លះពាក់មួកស្លឹកត្នោតមានក្រមាអំបោះចងសង្កត់ពីលើមួក ខ្លះយកក្រមាមកបង់នៅកបត់ជាពីរ ចងប្រទាក់ទម្លាក់ចុងជាយមកលើទ្រូងខាងមុខ ចំណែកអ្នកខ្លះទៀតពាក់វ៉ែនតាការពារពន្លឺមានពណ៌ទឹកតែថ្លា។ ខ្ញុំទៅដល់ពុំនិយាយស្តីអ្វី គ្រាន់តែលើកដៃជម្រាបសួរគេទាំងអស់គ្នា ដែលជាកិច្ចស្វាគមន៍តាមទំនៀមទម្លាប់ប្រពៃណីជាតិ។

ប្រមាណជាដប់នាទីក្រោយមក រថយន្តចំណុះមួយតោនពណ៌បៃតងស្រងាត់មកប្រត្យក្សនៅចំពោះមុខយើង។ នៅលើរថយន្ត ខ្ញុំឃើញវត្តមានសមមិត្តប្រធាន និងអនុប្រធានរួចទៅហើយ។ អ្នកទាំងពីរអង្គុយលើរថយន្ត មានទឹកមុខញញឹមពព្រាយ។ ពេលរថយន្តពន្លត់ម៉ាស៊ីន សមមិត្តប្រធានបើកទ្វារបាំងខាងមុខចុះមក ហើយបញ្ជាឲ្យសមាជិកទាំងអស់រៀបចំឡើងឡាន។

មិត្តម្នាក់សួរ ៖

- តើយើងត្រូវចេញដំណើរទៅឥឡូវនេះឬ?

សមមិត្តប្រធានងក់ក្បាលបណ្តើរ ឆ្លើយតបបណ្តើរ ៖

- ហ្នឹងហើយ... យើងប្រញាប់ស្រូតពីព្រលឹមបន្តិច។

និយាយរួច សមមិត្តប្រធានក៏ចង្អុលបង្ហាញកន្លែងក្បែរបង្អួច រួចបង្គាប់ឲ្យខ្ញុំទៅ

អង្គុយនៅទីនោះ។

ខ្ញុំឡើងទៅអង្គុយនៅក្បែរបង្អួចយ៉ាងសុភាពរាបសា។ ខ្ញុំឃើញកាំភ្លើងបញ្ឈរប្រហែលជាប្រាំ ឬប្រាំមួយដើម នៅជាប់នឹងកៅអីរបស់សមមិត្តអនុប្រធាន។

នេះគឺជាភារកិច្ចចុះមូលដ្ឋានរយៈពេលបីខែ កាលពីឆ្នាំ១៩៨៣។ សមាជិកទាំងអស់មានចំនួនដប់មួយនាក់ ប្រុសដប់នាក់ រីឯស្រីគឺមានតែរូបខ្ញុំម្នាក់ឯងគត់ ទាំងអស់គ្នាសុទ្ធតែជាកម្មាភិបាល មកពីក្រសួងមន្ទីរនានា។ យើងចុះទៅពង្រឹងឃុំជា និងឃុំទ្រៀក ដែលឋិតនៅក្នុងស្រុកមេម៉ត់ ខេត្តកំពង់ចាម។ ពេលរថយន្តបរចេញផុតពីរដ្ឋធានីភ្នំពេញកាលណា ទីវាលល្វឹងល្វើយនៃវាលស្រែ បានលាតត្រដាងសន្ធឹងរាប់គីឡូម៉ែត្រឯនាយឆ្ងាយ។ ដើមត្នោតច្រូងច្រាងដុះលើទួល... លើភ្លឺដែលបែងចែកជាក្រឡាចត្រង្គខ្វាត់ខ្វែង។ សកម្មភាពរថយន្តរត់ក្នុងល្បឿនមធ្យម ... ទៅមុខជានិច្ច... រីឯទេសភាព និងគេហដ្ឋានអ្នកស្រុកដែលសង់តាមបណ្ដោយផ្លូវជាតិ មានចលនាហាក់ដូចជារត់បកត្រឡប់ថយក្រោយវិញឥតនឿយណាយ បញ្ច្រាស់រថយន្តដែលខ្ញុំកំពុងតែជិះ។ ជាញឹកញាប់ណាស់ ដែលអ្នកបើកបរចាប់ហ្វ្រាំងបន្ថយល្បឿន ព្រោះមានជង្ហុកកាត់ផ្លូវជាកង់ៗ ដែលជាការរំខានក្នុងការបើកបរពន់ពេកកន្លង។ អ្នកដំណើរទាំងឡាយ ដែលកាលពីទើបតែឡើងជិះឡានដំបូង គេរីករាយ... សើចក្អាកក្អាយ... បង្អាប់គ្នាចុះឡើង បង្កឲ្យមានសំណើចផ្ទុះម្ដងម្កាល... ប៉ុន្តែលុះរថយន្តចេញមកដល់ជនបទ សំឡេងសើចលេងក៏បន្ថយបន្តិចម្ដងៗ រហូតទាល់តែស្ងើរតែបាត់ស្ងាត់។ ម្នាក់ៗប្រឹងទប់ខ្លួន ពីព្រោះបើមិនដូច្នេះទេ គេប្រាកដជាធ្លាក់ពីលើកៅអីចុះមកកម្រាលជាមិនខានឡើយ។ ជួនកាលទៀត ខ្លួនគេម្នាក់ៗមានលក្ខណៈដូចជាគ្រវែងគ្រវី ម្ដងចង់ហក់ទៅលើ... ម្ដងផ្អៀង





ទ្រេតមកខាង... ម្ដងផ្ងារទៅក្រោយ។ ខ្លះទៀតទង្គិចក្បាលនឹងបាំងខាងមុខ ធ្វើមុខជូរហ្វូញ។ ខ្ញុំក៏អង្គុយត្រៀមខ្លួនរបៀបប្រុងប្រយ័ត្ន ដូចជាគេទាំងអស់គ្នាដែរ។ ខ្ញុំនឹកដល់ភាពអវិជ្ជានៃប្រជាជនភាគច្រើនរបស់យើង ដែលមានលក្ខណៈដូចពាក្យបុរាណលោកពោលថា "ខឹងគោ វាយរទេះ" ដល់លំបាក គឺលំបាកយើងទាំងអស់គ្នា គឺទាំងអ្នកធ្វើ និងទាំងអ្នករងអំពើ។ ឱ! ថ្ងៃណាទៅ ទើបយើងភ្ញាក់រឭកមូលត្រកូលជួបជុំឥតមានជម្លោះបន្តយ៉ាងដូច្នេះទៀត? បើនៅតែមានសង្គ្រាម ទោះតិចទោះច្រើន នៅទីបំផុត លទ្ធផលដែលយើងបានទទួល គឺការខូចខាត... តួយ៉ាងដូចជាផ្លូវថ្នល់ ដែលជាការចាំបាច់សម្រាប់ធ្វើដំណើរទាក់ទងគ្នា ក៏ត្រូវកាត់ផ្ដាច់ឥតស្រាកស្រាន្តដែរ។

ហេតុអ្វីក៏យើងមិនយកគំរូរបស់វៀតណាម ដែលគេធ្វើសង្គ្រាមចំណេញអគារណាចាស់ៗ គេផ្លាស់ឲ្យទៅជាអគារថ្មីឡើងវិញ។ គេពង្វក់ជនបរទេសឲ្យរួមចំណែកកសាងប្រទេសគេឲ្យរីកចំរើនលូតលាស់ ត្រសាយត្រសុំ ថ្កុំថ្កើង រុងរឿងជាលំដាប់លំដោយហូរហែ រហូតទល់តែគេបានឯករាជ្យពេញបរិបូរណ៍។

ខ្ញុំដកដង្ហើមធំដើម្បីបន្ធូរការតានតឹងអ្វីមួយ ដែលកប់នៅក្នុងចិត្តហើយពុំអាចថ្លែងចេញបាន។

សមមិត្តប្រធានដែលអង្គុយនៅបាំងខាងមុខ បានឃើញទិដ្ឋភាពច្បាស់ជាងអ្នកដែលអង្គុយនៅបាំងខាងក្រោយ ក៏លាន់មាត់សរសើរអ្នកបើកបរ ៖

- បើកុំតែអ្នកបើកបរមានទេពកោសល្យខ្ពស់ កុំអីយើងមិនដឹងជាយ៉ាងណាទេ ព្រោះជង្ហុកខ្លះធំៗណាស់ អាចបណ្ដាលឲ្យរថយន្តផ្អៀងក្រឡាប់បាន។

មិត្តម្នាក់លូកមាត់ឆ្លើយឆ្លងបន្តសម្ដីពីសមមិត្តប្រធានក្រុម ដែលទើបតែនិយាយ

ផុត ៖

- ទោះជាអ្នកល្មោភដេកយ៉ាងណា ក៏ធ្មេចមិនជិតដែរ បើក្រឡុកឥតស្វាងយ៉ាងនេះ។

សកម្មភាពនៅក្នុងរថយន្តធ្លាក់ចុះដុនដាប... ប៉ុន្តែ ទាំងអស់គ្នាបែរជាសើចសប្បាយទៅវិញ បង្កឲ្យបរិយាកាសបានធូរស្រាលជាងមុនបន្តិចដែរ...។

ផុតពីផ្លូវក្រហេងក្រហូង រថយន្តបានបរយ៉ាងស្រួលលើផ្លូវដែលមានស្នាមជួសជុលនៅថ្មីៗ។ ខ្ញុំអង្គុយយ៉ាងស្ងៀមស្ងាត់ដូចគេទាំងពួងដែរ គយគន់ទេសភាព និងជីវភាពអ្នកស្រុក ទាំងអារម្មណ៍រីករាយ... ថ្លា... ក្នុងចិត្ត ដោយនឹកមិនអស់ចិត្តសោះថា ហេតុអ្វីបានជារូបខ្ញុំបិតនៅក្នុងរថយន្តដូច្នេះទៅវិញ ?

រថយន្តបរទៅមុខ... ឆ្ងាយពីភូមិអ្នកស្រុកបន្តិច ខ្ញុំឃើញមូលដ្ឋានទ័ពប្រជាជនបដិវត្តកម្ពុជា ដែលសង់ជារោងដោលតូចៗបីជួរ ប្រក់ស្លឹកត្នោត។ ទីធ្លាស្អាតភ្លឹងឥតមានសំរាមមួយទង ខាងមុខមានសួនច្បារតូចមួយ ដែលមានដាំដើមផ្កាម៉ោងដប់រីកក្រហមច្រាល។ នៅចំកណ្តាលសួននេះមានបង្គោលឈើពណ៌ស ព្រមទាំងចងទង់ជាតិសាធារណរដ្ឋប្រជាមានិតកម្ពុជា បក់រវិចៗតាមកម្លាំងខ្យល់នារដូវប្រាំង។ នៅខាងក្រោយរោង មានស្នូហាលខោអាវវែងមួយ។ ដោយហេតុរថយន្តបរលឿន ខ្ញុំពុំអាចគយគន់ឲ្យបានល្អិតល្អន់នូវអ្វីៗផ្សេងទៀត ដែលមាននៅទីនោះ។ ប៉ុន្តែខ្ញុំឃើញជុំដែករាងមូលធំមួយ ចងព្យួរនៅនឹងដើមស្វាយ ដែលមានមែកសាខាចោលម្លប់ត្រឈឹងត្រឈៃគួរជាទីមនោរម្យ។ ការដែលខ្ញុំចាប់អារម្មណ៍ទៅលើជួង ព្រោះពេលនោះ គឺមានយុវជនម្នាក់កំពុងឈរកាន់អន្លូងវាយ ដើម្បីប្រកាសប្រាប់មិត្តភក្តិដែលនៅទីជិតឆ្ងាយឲ្យមកជួបជុំគ្នា ប្រហែលជាមានកិច្ចការអ្វីសំខាន់ហើយ... ដែល





ខ្ញុំមិនអាចដឹងបានទេ ព្រោះខ្ញុំនៅលើឡាន សំឡេងជួងបានរសាត់មកអង្រួនបេះដូងខ្ញុំ ឲ្យរឭកនឹកឃើញដល់សំឡេងជួង កាលពីសម័យប្រល័យពូជសាសន៍ ដែលធ្វើឲ្យខ្ញុំខ្លាចរន្ធត់ឥតឧបមា។ ខ្ញុំនឹកឆ្ងល់ណាស់ថា ហេតុអ្វីក៏ជួងដែលយុវជនវាយនៅពេលនេះ ឥតធ្វើឲ្យខ្ញុំតក់ស្លុតសោះយ៉ាងដូច្នេះ? បើរូបរាងជួងនោះ គឺជាជុំកង់ឡានច្រេះចាប់កញ្ចាស់មួយ ដូចបេះបិតទៅនឹងជួងកាលពីសម័យខ្មែរក្រហម ហើយសំឡេងដែលបន្លឺឡើងទៀត ក៏ឥតមានខុសគ្នាបន្តិចណាដែរ។ ទស្សនីយភាពដ៏សែនខ្លោចផ្សាកាលពីអតីតកាលក្នុងសម័យប្រល័យពូជសាសន៍ បានដាស់ក្នុងអារម្មណ៍ខ្ញុំ ដូចជាខ្សែភាពយន្តកំពុងបញ្ចាំង។ ដំណើររឿងមានដូចតទៅ :

...ម៉ោងដប់មួយយប់ទៅហើយ ស្នូរជួងបន្លឺឡើងដើម្បីប្រកាសឲ្យដឹងថា ដល់ម៉ោងសម្រាក។ យុវនារី យុវជន ដែលកំពុងសម្រុកធ្វើការងារលើកទំនប់ទូលគ្រួសដែលបិតនៅក្នុងខេត្តតាកែវ បានដាក់ដងធ័កពីលើស្មា រួចនាំគ្នាដើរសំដៅទៅសម្រាកនៅរោងដោលវែងៗជាច្រើនជួរ ដែលសង់តាមបណ្តោយផ្លូវលំក្រាលក្រួសក្រហម។

រោងដោលនោះមានបណ្តោយម្ភៃម៉ែត្រ ទទឹងបួនម៉ែត្រ ចំណុះមនុស្សមួយរយនាក់។ នៅពេលសម្រាន្ត ត្រូវយកជើងទល់គ្នា ដោយទុកចន្លោះផ្លូវដើរចំនួនកន្លះម៉ែត្រ រីឯកំពស់ពីដីមកសំយ៉ាបដំបូលទាំងសងខាងរោងដោលវិញ ក៏មានកំពស់កន្លះម៉ែត្រដែរ។

យុវនារីយុវជនទាំងអស់ដើរតាមក្រុម ឆ្ពោះទៅកាន់ទីកន្លែងរៀងៗខ្លួន ដោយកាយប្បកិរិយាស្ងៀមស្ងាត់។ ចំណែកឯរូបខ្ញុំក៏ចូលទៅសម្រាកជាមួយនឹងគេដែរ។ យុវនារីម្នាក់ដែលនៅសម្រាកក្បែរខាងខ្ញុំឈ្មោះ "ដា" ។ គ្រាន់តែដាដាក់ខ្នងដល់

កន្ទេល គេក៏ដេកលក់ភ្លាមមួយរំពេច ដោយពុំទុកឲ្យពេលវេលាដ៏មានតម្លៃនេះកន្លងផុតទៅឥតប្រយោជន៍ឡើយ យ៉ាងហោចណាស់ ក៏ខ្លួនគេបានចម្រាញ់យកកម្លាំងសម្រាំង សម្រាប់ទុកពេលធ្វើការនៅវេលាថ្ងៃស្អែកដែរ។ រីឯខ្លួនខ្ញុំវិញសម្រាកមិនលក់សោះ ព្រោះម៉្យាងខ្ញុំចុកចាប់ពើតនឹងដំបៅនៅត្រង់កែងជើង ដែលខ្ញុំខំប្រឹងធ្វើចលនាជញ្ជូនដីចុះឡើងៗ ម៉្យាងកន្លែងនោះតូចចង្អៀតរកតែរេខ្លួនក៏ពុំរួច ហើយម៉្យាងទៀត ភ្លៀងបង្អុរមកជ្រាបពីកន្ទេលស្លឹកត្នោតសើមទទឹកខ្ទងជោក... ពេលខ្យល់បក់មកម្តងៗ សាចតំណក់ទឹកភ្លៀងចូលមកក្នុងរោងដោលតាមចន្លោះប្រឡោះទាំងសងខាង វាលល្វឹងឥតមានជញ្ជាំងបិទបាំង ដោយទុកឲ្យខ្យល់ និងសន្សើម ឬតំណក់ទឹកភ្លៀងសាចចូលមកដោយសេរី។ ខ្ញុំអួលអាក់ក្នុងចិត្ត... តានតឹងសឹងតែស្រែកទ្រហោយំ... រួចនឹកគិតថា ទោះបីជាក្រតោកយ៉ាកយ៉ាងណា ក៏មិនវេទនាផ្អែកផ្លូវចិត្ត ដូចជារបបខ្មែរក្រហមនេះឡើយ។

ដោយសារភ្លៀងខ្លាំងពេក យើងទាំងអស់គ្នាក្រោកអង្គុយត្របោមក្បាលជង្គង់ផ្តុំគ្នានៅចំកណ្តាលរោងទាំងរងាញ័រញាក់... តត្រុន... ឥតមានភួយគ្របដណ្តប់ឲ្យបានកក់ក្តៅ... ក្រៅពីដណ្តប់ក្រមាកញ្ចាស់រហែកធ្លុះធ្លាយដោយអន្លើ និងមានអន្លើខ្លះក៏មានក្រណាត់ខុសពណ៌យកមកប៉ះប៉ុន ចំណែកឯអន្លើខ្លះទៀត ក៏ទុកចោលឲ្យនៅធ្លុះរហូត។ ខ្ញុំឥតបានធ្មេចមួយស្រឡេតសោះ។ នៅម៉ោងប្រហែលជាមួយអធ្រាត្រ ពេលមាន់ចាប់រងាវដំបូង ភ្លៀងចាប់រាំង ឈ្លបពីរនាក់ដើរតម្រង់មករោងដែលខ្ញុំសម្រាក រួចខ្ញុំឃើញនារីអ្នកយាមប្រចាំការ (រៀងរាល់យប់នៅកន្លែងសម្រាកតែងតែមានចាត់តាំងនារីពីរនាក់យាមផ្លាស់វេនគ្នា) ម្នាក់ដើរចូលមកក្នុងរោង រួចឱនដាស់មិត្តនារីដាខ្សឹបៗ ដែលគ្នាទើបតែប្រះខ្លួនដេកបានប្រហែលជាដប់ប្រាំនាទី





មុននេះបន្តិច ឲ្យក្រោកឡើង។ ដោយហេតុមិត្តនារីដានៅដេកក្បែរខ្ញុំ ទើបខ្ញុំឮសំឡេងនារីយាមប្រចាំការនិយាយ ៖

- កុំយកអីវ៉ាន់តាមខ្លួន!
- នរណាហៅ? (មិត្តនារីដាសួរ)
- ឈ្លប (នារីយាមឆ្លើយកំបុត របៀបភ័យស្លន់ស្លោ)
- ឱ! ម៉ែអើយ! (មិត្តនារីដាឧទានទាំងរន្ធត់ញាប់ញ័រ)

រួចមិត្តនារីដា ក៏ស្ថិតនៅក្នុងសភាពស្ងប់ស្ងាត់ ហើយងើបដើរតាមនារីយាមប្រចាំការចេញបាត់ទៅ។

គ្រាន់តែមិត្តនារីដាចេញដល់ក្រៅរោង ខ្ញុំក៏ក្រោកអង្គុយជាថ្មីម្តងទៀត គយគន់ស្រមោលមិត្តនារីរួមការដ្ឋាន ទាល់តែបាំងបាត់នឹងអ័ព្ទ។ សំឡេងកង្កែប ហ៊ីង ក្អាត់យំលាន់ទ្រហឹង ហាក់ដូចជាសប្បាយនឹងលោតលេងនឹងទឹកថ្លុក ដែលដក់តាមកន្លែងក្រហេងក្រហូងទាំងឡាយ។

នៅឯនភាល័យ ព្រះចន្ទដប់បីរោចបញ្ចេញពន្លឺព្រាលៗ ពីពពកសខាប់អ័ព្ទចុះសសំព្រុស មើលមិនឃើញទិសតំបន់អ្វី ក្រៅពីស្រមោលខ្មៅស្លុងៗនៃដើមឈើទាំងឡាយ ដែលខ្ញុំឧបមាថា ជាស្រមោលអសុរកាយចាំថែរក្សាព្រៃព្រឹក្សា។

នៅលើរទេះសេដ្ឋកិច្ច មាន់គកដែលគេចងជើងទុកបម្រុងធ្វើម្ហូបនៅវេលាថ្ងៃស្អែក ក៏ចាប់ទទះស្លាបរងាវលាន់រំពងរន្លឺនឡើង ទើបខ្ញុំដឹងថាជិតភ្លឺហើយ ខ្ញុំទន់ខ្លួនដូចសំឡី បន្តិចក្រោយមក ស្នូរជួងវាយដាស់ និងប្រាប់ពីពេលដែលត្រូវចាប់ផ្តើមសម្រុកធ្វើការងារទៀតហើយ។ ខ្ញុំសែនក្តៅក្រហាយស្ទើរដាច់ដង្ហើម នឹកស្អប់គ្នាន់ក្នាញ់នឹងសំឡេងជួងចង្រៃនេះដំក្នុងចិត្ត។

ខ្ញុំក្រោកឈរឡើងទាំងទ្រេតទ្រោត ដូចមនុស្សស្រវឹងស្រា ព្រោះអាហារដែលខ្ញុំទទួលទានកាលពីល្ងាច មានតែបបរាវមួយវែក និងសម្លព្រលិតទឹកថ្លាឈ្មោងមួយចានគោម ហូបរួមគ្នាមួយវង់បួននាក់។ ខ្ញុំបកក្រមាដែលដណ្ដប់ខ្លួនយកទៅជូតក្បាលវិញ រួចបោះជំហានទាំងហេវភ័យខ្លាច ដើរតម្រង់ទៅចាប់ដងវែកនិងបង្គី ដើរឆ្ពោះទៅការដ្ឋាន (ពុំមែនមានតែរូបខ្ញុំម្នាក់ទេ ដែលមានលក្ខណៈទ្រុឌទ្រោមបែបនេះ គឺជាទូទៅៗហើយដែលម្នាក់ៗបាត់បង់សម្ផស្សជាយុវនារី។ រូបរាងកាយរបស់គេ បើក្រឡេកមើលមួយភ្លែត នៅពេលខ្លះគេអាចច្រឡំថា ជានារីចាស់ទៀតផង)។

សេចក្ដីភ័យខ្លាចបានជំរុញយើងឲ្យធ្វើការងារបន្ត។ មិត្តខ្ញុំកាប់ដីសើមហើយស្អិតដាក់ពេញបង្គី ខ្ញុំលើកវែកសឹងតែពុំរួច ព្រោះដីដែលជ្រាបទឹកមានទម្ងន់ទ្វេមួយជាពីរ... ជាបីដង សមខ្ញុំមានទុព្វលភាពនឹងការអត់ងងុយ... និងជំងឺដំបៅជើង... និងអាហារឥតជីវជាតិ ធ្វើឲ្យខ្ញុំវែកឡើងបានតែពាក់កណ្ដាលទំនប់ ខ្លួនខ្ញុំក៏រមៀលធ្លាក់ចុះមកក្រោមឯបាតទំនប់វិញ រួចហើយអ្វីៗក៏ងងឹតសូន្យសុងក្នុងពិភពអន្ធការ។

នៅពេលដែលខ្ញុំភ្ញាក់ស្មារតីឡើងវិញ គឺខ្ញុំដេកលើគ្រែរនាបឫស្សី បណ្ដោយប្រវែងមួយម៉ែត្រប៉ែតសិប ទទឹងប្រវែងសូន្យម៉ែត្រហុកសិប។ ខ្ញុំធុំក្លិនឆ្អាប... ខ្លួនខ្ញុំដូចជាឈឺចុកចាប់គ្រប់សរសៃសរសូងទាំងអស់ រីឯក្បាលដែលខ្ញុំកើយលើសំពៀតកញ្ចាស់របស់ខ្ញុំក៏ឈឺដែរ។

មិត្តភក្ដិពីរនាក់ដែលសែងខ្ញុំយកទៅមន្ទីរពេទ្យ អង្គុយចុងជើងខ្ញុំ ទាំងស្ងៀមស្ងាត់។ ពេលឃើញខ្ញុំបើកភ្នែក គេខំប្រឹងញញឹមទាំងស្ងួតស្ងប់ ដោយចិត្តត្រេកអរព្រោះដឹងថា ខ្ញុំប្រហែលជាមិនស្លាប់ទេ។





ខ្ញុំខំប្រឹងបង្ហើបបបូរមាត់ ដែលវាស្អិតជាប់ដូចគេបិទជ័រកាវ ឲ្យរបើកឡើងដើម្បីថ្លែងអំណរគុណដល់មិត្ត និងនិយាយបន្ថែម៖

- ប៉ុន្មានម៉ោងដែលខ្ញុំឥតដឹងខ្លួន... ខ្ញុំដូចជាមានសេចក្ដីសុខច្រើនណាស់... ខ្ញុំមិនចង់ភ្ញាក់ឡើងវិញ មើលឃើញអំពើទារុណអមនុស្សធម៌ទាំងឡាយឡើយ។

ឯចិត្តក៏នឹកឃើញដល់នារីដា ទើបបន្តសំណួរសួរទៅមិត្តទាំងពីរ៖

- មិត្តដាមានវិលមកវិញទេ?

មិត្តទាំងពីរមើលមុខគ្នាអេះអុញៗមិនចង់ឆ្លើយប្រាប់ខ្ញុំ... មួយសន្ទុះទើបគេដាច់ចិត្តនិយាយ៖

- អត់ឃើញមកវិញទេ... ប្រហែលជាគេទៅរហូតហើយ... ព្រោះកាលពីថ្ងៃ ខ្ញុំឃើញមិត្តដាយកកូនកញ្ចប់អ្វីទៅឲ្យមិត្តយុវជនម្នាក់ ដែលនៅក្នុងភូមិយើងដែរ... អង្គការចោទប្រកាន់ធ្ងន់ធ្ងរណាស់ថា អ្នកទាំងពីរខុសសីលធម៌។

ឮពាក្យខុសសីលធម៌ ខ្ញុំលាន់មាត់៖

- ពុទ្ធោអើយ!... ហេតុអ្វីក៏ឃោរឃៅព្រៃផ្សៃម្ល៉េះ!

យើងទាំងអស់គ្នាដឹងជាស្វ័យប្រវត្តិទៅហើយថា គេយកមិត្តនារីដាទៅសម្លាប់ព្រោះតែរឿងទាក់ទងនឹងមិត្តយុវជនកាលពីថ្ងៃ។

ខ្ញុំដេកដកដង្ហើមធំបើកភ្នែកភ្លឹះៗ មើលដំបូលពិដានមន្ទីរពេទ្យស្រុក... រួចរក្រសែភ្នែកមើលទិដ្ឋភាពខាងក្រៅតាមបង្អួច ដែលបើកចំហទាំងដួងចិត្តស្រពោនស្រពាប់ និងលាយឡំដោយក្ដីអស់សង្ឃឹម។ សំឡេងជួងបន្លឺឡើងជាសញ្ញាប្រាប់អ្នកជំងឺឲ្យទៅបរិភោគអាហារនៅពេលថ្ងៃត្រង់ (នៅមន្ទីរពេទ្យ គេហូបបាយថ្ងៃត្រង់នៅម៉ោងប្រាំបួន ឯពេលល្ងាច ការហូបចុកប្រព្រឹត្តទៅនៅម៉ោងបួន)។ មិត្តខ្ញុំម្នាក់

បានយកបបររាវមកឲ្យខ្ញុំមួយចាន និងអំបិលគ្រាប់ ប្រាំប្រាំមួយគ្រាប់តូចៗ។ គេគ្រាហ៍ខ្ញុំឲ្យងើបឡើង រួចបញ្ចុកបបរ ខ្ញុំខំប្រឹងហុតបបរទាល់តែអស់ ខ្ញុំហាក់ដឹងថាមានកម្លាំងបន្តិចដែរ ព្រោះយូរខែឆ្នាំហើយ ខ្ញុំមិនដែលបានហូបចុកនៅពេលម៉ោងថ្មើរហ្នឹងទេ...។ បបរដែលមិត្តខ្ញុំយកមកឲ្យខ្ញុំអម្បាញ់មិញ គ្មានគ្រឿងគ្រៅ គ្មានត្រីសាច់ឯណាក្រៅពីដុំអំបិលប្រាំប្រាំមួយគ្រាប់តូចៗហុតលាយគ្នា ប៉ុន្តែហេតុអ្វីក៏ផ្តល់នូវឱជារសក្នុងមាត់ខ្ញុំម្ល៉េះ...។ មិត្តខ្ញុំទាំងពីរនាក់ត្រឡប់ទៅការដ្ឋានវិញ ក្រោយពីហូបចុកនៅឯមន្ទីរពេទ្យរួច។ ការសម្រាកពីពលកម្មដ៏សែនធ្ងន់ធ្ងរនេះ បានប្រហែលជាបីថ្ងៃ សុខភាពខ្ញុំឃើញបានប្រសើរ។ ពេលដែលសុខភាពបានប្រសើរដូច្នេះ ខ្ញុំមិននៅទំនេរទេ គឺជួយបោសសម្អាតមន្ទីរពេទ្យ ជួយដេរខោអាវអ្នកជំងឺដូចគ្នា កាលណាគេពឹងពាក់ខ្ញុំ។ ពេលល្ងាចនារីពេទ្យម្នាក់បានមកប្រាប់ខ្ញុំថា ពីរថ្ងៃទៀត ខ្ញុំត្រូវត្រឡប់ទៅការដ្ឋានវិញ។ ឮដំណឹងនោះភ្លាម ខ្ញុំធ្លាក់ថ្លើមក្តុក ប៉ុន្តែឥតមានហ៊ានប្រកែកតវ៉ាអ្វីទេ គ្រាន់តែនឹកថា ឱ! ពលកម្មឥតល្ហែអើយ... ប្រយុទ្ធខ្លាំងក្លាទៀតហើយ។

ខ្ញុំកំពុងតែអង្គុយអស់សង្ឃឹម ស្រាប់តែឃើញគេសែងបងស្រីខ្ញុំពីភូមិមកមន្ទីរពេទ្យស្រុក ដែលខ្ញុំក៏នៅទីនោះដែរ។ ពេលល្ងាចនេះ ខ្ញុំឥតហូបបាយបបរ (អ្នកតាកែវហៅ បបរ ថា "បាយបបរ" ) នៅផាងរួមទេ ដោយខ្ញុំលួចចាក់បបរចំណែកខ្ញុំចូលមកក្នុងចានចំណែកបងស្រីខ្ញុំ ហើយប្រញេបប្រញាប់មកកន្លែងវិញ។ គេដាក់បងស្រីខ្ញុំលើគ្រែទំនេរមួយ ដែលគេទើបយកខ្មោចទៅកប់ កាលពីពេលរសៀល។ បងស្រីខ្ញុំគ្រាន់តែក្រឡេកឃើញខ្ញុំ ភ្នែករបស់គាត់បញ្ចេញរស្មីដោយក្តីត្រេកអរហួសនិស្ស័យ។ រូបរាងគាត់ស្គមស្គាំងឃើញតែស្បែកដណ្តប់ឆ្អឹង។

អ្នកសែងម្នាក់ដែលមកពីភូមិ លួចខ្សឹបប្រាប់ខ្ញុំ ៖





- បងស្រីមិត្តនារីឯងឈឺដេកនៅមន្ទីរពេទ្យឃុំយូរហើយ គ្មានថ្នាំសង្កូវអ្វីព្យាបាលទេ ទើបប្រធានមន្ទីរពេទ្យឃុំ សម្រេចឲ្យយកមកមន្ទីរពេទ្យស្រុក។

យើងជាអ្នកសែងអ្នកជំងឺ ត្រូវត្រឡប់ទៅភូមិវិញទាំងយប់ ហើយពីមន្ទីរពេទ្យស្រុកទៅភូមិមានចម្ងាយប្រហែលជាបួនគីឡូម៉ែត្រ... មិត្តនារីអើយ ទៅដល់ភូមិមិនដឹងជាគេទុកបបរឲ្យយើង ឬក៏គេភ្លេច?... ឮសម្តីពួអ្នកសែងអ្នកជំងឺ ខ្ញុំសម្លឹងមើលទៅចានបបរដែលដាក់នៅចុងជើងគ្រែ... មិនដឹងជាគិតយ៉ាងណា ខ្ញុំគ្រាន់តែដកដង្ហើមធំដើម្បីជម្រុះការតានតឹងដែលគរនៅក្នុងទ្រូង។

ខ្ញុំអង្គុយមើលបងស្រីទាំងក្តីរន្ធត់ សក់គាត់កន្ទ្រើង ហាក់ដូចជាពុំដែលស្គាល់ការកក់ ឬសិត គាត់ដើរពុំរួចទេ ព្រោះគាត់កើតពិសជើង គាត់ចុកចាប់ខ្លាំងពេកធ្វើឲ្យគាត់សម្រាន្តពុំបានសោះ គាត់អង្គុយច្រងុក រួចខំប្រឹងនិយាយសួរសុខទុក្ខដោយពុំគិតគូរពីជំងឺរបស់ខ្លួនឡើយ ៖

- អូនឯងឈឺអីដែរ?

ខ្ញុំឆ្លើយដោយសុភាវគតិ ៖

- ខ្ញុំគ្រុន តែឥឡូវបានធូរស្រាលហើយ។

ដោយខ្ញុំមិនចង់ឲ្យគាត់និយាយច្រើនតទៅទៀត ក៏លើកបបរពីរចំណែករួមគ្នាដែលមិនទាំងពេញមួយចានផង មកជូនបងស្រីទាំងអស់ ដោយមនោសញ្ចេតនាបងប្អូនជាប់ប្រទាក់ខ្សែលោហិត... ប៉ុន្តែបងខ្ញុំគ្រវីក្បាលជាសញ្ញាប្រកែក ហើយខំឆ្លើយព្រឹតិចៗ ៖

- បងអត់ឃ្លានទេ... បងស៊ូស្លាប់ប្រសើរជាង... បងស្អប់បបរចង្រៃនេះណាស់... បងនឹកម៉ែ នឹកឪ នឹកបងប្អូនយើងដែលបែកទៅ... បងឃ្លាននំចំណី និងអាហារ

សព្វសារពើ... ប៉ុន្តែបងមិនចង់ហុតបបរទឹកកាវកខ្វក់នេះទេ...។

បងស្រីខ្ញុំឈប់និយាយ រួចសម្លឹងមុខខ្ញុំយ៉ាងយូរ ហាក់ចង់ថតរូបខ្ញុំទុកក្នុងកែវភ្នែកទាំងពីររបស់គាត់... បន្ទាប់មកគាត់ក៏បន្តសម្តី... ប៉ុន្តែសម្តីនោះមិនជាប់ឃ្លាដែលគាត់បាននិយាយរួចមកហើយ តែគាត់បែរជានិយាយ ៖

- បើអត់ពីបងទៅ... អូនឯងកុំកើតទុក្ខខ្លាំងពេកណា៎... ខំប្រឹងតាំងស្មារតីឲ្យនឹងន... ថ្វីត្បិតតែយើងមានគ្នាតែពីរនាក់បងប្អូនក៏ដោយ... ធ្វើម្តេចជីវិតវាមិនទៀង...។

ខ្ញុំឃើញបងស្រីខ្ញុំនិយាយចម្លែក ក៏ប្រញាប់ឆ្លើយកម្លាកាត់គាត់ ៖

- បងឥតទៅណាចោលខ្ញុំទេ... បន្តិចទៀត យើងជួបជុំឪពុកម្តាយ បងប្អូនយើងវិញហើយ... យើងនឹងបានអាហារហូបចុកគ្រប់គ្រាន់...។

ពេលនិយាយដល់កន្លែងនេះ ពោះរបស់ខ្ញុំរមូល។ ឮពោះខ្ញុំរមូល បងស្រីក៏និយាយជំរុញឲ្យខ្ញុំហុតបបររបស់ខ្ញុំ និងបបររបស់គាត់រួមគ្នាទៅ។ ខ្ញុំរលីងរលោង និងអួលអាក់ក្នុងចិត្ត សឹងតែលើកបបរនោះហុតមិនរួច។

បងខ្ញុំបន្តសម្តី ៖

- បងនឹកបងប្អូនខ្លាំងពេក អារម្មណ៍របស់បងស្រមៃឃើញគេទាំងអស់នោះ មកឈរក្បែរគ្រែបង... បងលោដៃស្រវាំរកគេ ហើយបងក៏ធ្លាក់ពីលើគ្រែ។

បងខ្ញុំបញ្ចប់សម្តី រួចសួរខ្ញុំ ៖

- អូនឯងទៅការដ្ឋានវិញថ្ងៃណា ?

ខ្ញុំមិនចង់ឆ្លើយប្រាប់ពីដំណឹងបែកគ្នាឲ្យគាត់ដឹង ក្រែងលោគាត់រឹតតែព្រួយ ប៉ុន្តែដោយសារគាត់រន្ថើនសំណួរ ខ្ញុំពុំអាចរកលេសភូតកុហកគាត់បាន ក៏ឆ្លើយតាមត្រង់ ៖





- ពីរថ្ងៃទៀត។

បងស្រីខ្ញុំពុំនិយាយដូចម្តេច គាត់ក៏ប្រះខ្លួនដេកសំងំ ដោយមានខ្ញុំជាអ្នកជួយលើកដាក់ថ្នាក់ថ្នម។ គ្រែដែលបងស្រីខ្ញុំសម្រាន្ត ជាគ្រែអ្នកជំងឺរាគ ដូច្នេះក្លិនស្អុយឆ្អេះឆ្អាប សឹងតែធ្វើឲ្យអ្នកជំងឺថ្មីនេះដាច់ខ្យល់ស្លាប់មួយរំពេច។ ពេលឃើញបងស្រីខ្ញុំសំងំ ខ្ញុំក៏ទៅកើបផេះយកមកចាក់រោយតាមប្រឡោះរនាប និងបាចសាចក្រោមគ្រែ រួចកើបប្រមូលកម្ទេចកំទីលាមកដែលនៅសេសសល់យកទៅចោល។ បន្ទាប់មក ខ្ញុំក៏យកខោអាវបងខ្ញុំដែលគេប្រមូលញាត់ក្នុងស្បោង យកទៅបោកគក់។ មិនយូរប៉ុន្មាន គ្រែដែលបងខ្ញុំកំពុងសម្រាន្តបានស្អាតបង្គួរ។ យប់នេះខ្ញុំដេកកំដរបងខ្ញុំ គាត់មានអាការៈសប្បាយចិត្តបន្តិច ហើយហាក់ដូចជាភ្លេចការឈឺចុកចាប់បានមួយគ្រាតូចដែរ។

# ២. ប្តេជ្ញា ផ្តាច់ការ

ថ្ងៃបែកគ្នាមកដល់ហើយ... ភ្លៀងចាប់ផ្តើមបង្អុរមក... បងស្រីខ្ញុំសម្លឹងមើលមុខខ្ញុំយ៉ាងយូរ រួចនិយាយជាចុងក្រោយ ៖

- ភ្លៀងអើយកុំរាំង។

ពាក្យបន់ស្រន់នេះបានសេចក្តីថា បងរបស់ខ្ញុំមិនចង់បែកពីខ្ញុំឡើយ។ ខ្ញុំសែនស្រណោះពាក្យសម្តី ដែលបងខ្ញុំទើបតែនិយាយផុតទៅ... មិនដឹងជាមានឥទ្ធិពលអ្វី ស្រាប់តែធ្វើឲ្យខ្ញុំរលីងរលោងទឹកភ្នែក។ ខ្ញុំគេចមុខចេញ ហើយអង្គុយសម្លឹងតាមបង្អួចដែលបើកចំហតែមួយចំហៀង មើលតំណក់ទឹកភ្លៀងដែលស្រក់បន្តៗគ្នាបង្កើតបានជាខ្សែសរសៃឆ្មារពណ៌សដាស់ពាសពេញផ្ទៃបរិយាកាស។ យើងទាំងពីរនាក់ឥតនិយាយឆ្លើយឆ្លងរកគ្នាទៀតទេ... ព្រោះក្នុងទ្រូងយើងអួលណែន និងជោកជាំទៅដោយទុក្ខសោកាឥតរសាយស្បើយ។ នារីពេទ្យម្នាក់ដើរចូលមកដោយមានកាន់សំបុត្របញ្ជាក់មួយសន្លឹកមកឲ្យខ្ញុំ។ ខ្ញុំទទួលយកដោយប្រុងប្រយ័ត្ន ថ្វីត្បិតតែក្រដាសមានដាមប្រឡាក់ទឹក ហើយតួអក្សរដែលសរសេរនោះមិនស្អាតយ៉ាងណាក៏ដោយ ក៏សំបុត្រនេះមានតម្លៃណាស់។ បើខ្ញុំគ្មានសំបុត្របញ្ជាក់សម្រាប់បង្ហាញប្រធានក្រុម នៅពេលដែលខ្ញុំវិលត្រឡប់ទៅកងវិញទេ ខ្ញុំមុខជាអត់បបរហូបចុកហើយ។ នារីពេទ្យដើរចេញទៅ... ភ្លៀងក៏ចាប់ផ្តើមរាំង ខ្ញុំមានអារម្មណ៍ភាំងមួយ





ភ្លែត ក៏របូតសំបុត្របញ្ជាក់ធ្លាក់ពីដៃ ប៉ើងរសាត់តាមកម្លាំងខ្យល់បក់ចូលទៅក្រោមគ្រែ។ ខ្ញុំឱនរើសសំបុត្របញ្ជាក់ នៅពេលខ្ញុំងើបឡើងវិញ ខ្ញុំទង្គិចនឹងម្រាមដៃដែលអង្អែលក្បាលខ្ញុំថ្នមៗ ហាក់ដូចជាថ្លាថ្លែងពីសេចក្តីនឹករឭក... ក្តីសន្តោសប្រោសប្រណី... ក្តីអាណិតអាសូរយ៉ាងខ្លាំងរបស់បងចំពោះប្អូន។ បងខ្ញុំគាត់បន្លឺវាចា ៖

- អូនទៅចុះ ភ្លៀងរាំងហើយ។

ខ្ញុំបើកសំពៀតដាក់សំបុត្រ... រួចលាបងស្រី និងអ្នកជិតខាង ហើយបោះជំហានចេញពីមន្ទីរពេទ្យស្រុក ទាំងស្រយុតស្រយុងចិត្ត និងដក់ជាប់នូវរូបរាងស្គមស្គាំងរបស់បងក្នុងអារម្មណ៍ ហើយនឹកគិត ៖

- បើបាយមិននឹក ទឹកមិនស្រេកតែយ៉ាងដូច្នេះ តើជីវិតអាចបន្តបានប៉ុន្មានថ្ងៃទៀត? បងស្រីខ្ញុំឈឺដាបដើរមិនរួច... ពេលបត់ជើងបត់ដៃ បាននរណាជួយលើកដាក់ថ្នាក់ថ្នម...។ ឱ! ព្រះអើយ តាំងពីតូចរហូតដល់ធំប៉ុណ្ណេះ ខ្ញុំមិនដែលប្រទះអ្នកគ្រប់គ្រងជាតិណាអាក្រក់ឃោរឃៅដូចពេលនេះទេ។

ខ្ញុំកំពុងតែស្លុងគំនិត ស្រាប់តែឮសន្ធឹករទេះគោមួយបរពីក្រោយ។ ខ្ញុំភ្ញាក់ព្រើតហើយខិតទៅក្បែរខាង ប៉ុន្តែអ្នកបរបែរជាបញ្ឈប់រទេះ ហើយហៅខ្ញុំឲ្យឡើងជិះ។ ខ្ញុំស្គាល់អ្នកបររទេះនេះច្បាស់ណាស់ ព្រោះគាត់ជាអ្នកស្រុកនៅភូមិខ្ញុំដែរ។ គាត់តែងតែដឹកម្ហូប និងបន្លែបង្ការយកទៅផ្គត់ផ្គង់កងយុវនារីយុវជន ឯទំនប់ទួលគ្រួស។ ខ្ញុំត្រេកអរពេក និយាយអរគុណអ្នកបររទេះតែមួយម៉ាត់ ហើយក៏ឡើងទៅអង្គុយនៅខាងក្រោយរទេះយ៉ាងស្ងៀមស្ងាត់។ រទេះចេះតែបរទៅមុខ គេពុំឮសូរអ្វីក្រៅពីសំឡេងកកិតកង់នឹងទូករទេះ ហើយនិងសំឡេងដេញគោឲ្យដើររបស់អ្នកបរ។ បរបានបន្តិច រទេះគោយើងបានបរហួសអ្នកទោស ខ្ញុំឃើញកងទ័ពពាក់ម្ហូកកាតិប

ពណ៌បៃតង ស្លៀកខ្មៅពាក់ខ្មៅ បង់ក្រមាសូត្រ ពណ៌ស្លាបសេក ពាក់ស្បែកជើងកង់ឡាន ជិះកង់ស្ពាយកាំភ្លើង (ខ្ញុំមិនស្គាល់ប្រភេទកាំភ្លើងទេ គ្រាន់តែដឹងថាជាកាំភ្លើងចិន) កងទ័ពនេះជិះកង់បណ្ដើរអ្នកទោសស្រីម្នាក់ និងក្មេងម្នាក់។ អ្នកទាំងពីរសុទ្ធតែចងស្លាបសេកទៅក្រោយ។ ឃើញដូច្នេះ ខ្ញុំក៏សន្និដ្ឋានថា ប្រហែលជាម្ដាយ និងកូន... គឺគេយកទៅសម្លាប់។ ឱ! មិត្តជាសម្លាញ់អើយ មុននឹងឯងស្លាប់ទៅ តើគេធ្វើទារុណកម្មឯងយ៉ាងណា?... គេវាយឯង... គេរំលោភឯង... ឬក៏គេចាក់ឯង? នឹកដល់ត្រង់នេះ ខ្ញុំភ័យបុកពោះ ត្រជាក់ដៃត្រជាក់ជើង ហើយអង្គុយត្រង់ខ្លួនភ្លឹង សឹងតែភ្លេចដកដង្ហើម។

ចំណែកឯអ្នកបររទេះវិញ ដេញគោញាប់មាត់ស្នេក ធ្វើឲ្យគោបោលហុយដីសំពោង... តាមស្មានប្រហែលគាត់ភ័យដូចខ្ញុំដែរក៏មិនដឹង ព្រោះយើងជាប្រជាជនថ្មីដូចគ្នា ប្រជាជនដប់ប្រាំពីរមេសា ឆ្នាំមួយពាន់ ប្រាំបួនរយ ចិតសិបប្រាំ។ ពេលជិតព្រលប់ ទើបរទេះយើងទៅដល់ការដ្ឋាន ខ្ញុំនឹកគិត ៖

- ប្រសិនបើខ្ញុំដើរដោយជើងវិញ ប្រហែលជាមកមិនទាន់គេហូបបាយល្ងាចទេ! ឱ! ម្ល៉េះសមខ្ញុំអត់បាយមួយល្ងាច ហើយព្រឹកឡើងធ្វើការងារធ្ងន់ធ្ងរទៀត ខ្លួនខ្ញុំអើយនឹងហេវហត់អស់កម្លាំងយ៉ាងណាទៅ... ស្រួលមិនស្រួលធ្លាក់ពីលើទំនប់ទៀតក៏មិនដឹង។

ខ្ញុំយកដៃបោសសំពត់អាវ ព្រមទាំងភើចក្រមារលាស់ជម្រុះធូលីចេញ ខ្ញុំឃើញមិត្តដែលសែងខ្ញុំទៅមន្ទីរពេទ្យស្រុក ដើរចូលមកទាំងទឹកមុខស្ងួតស្ងប់ រួចទាញដៃខ្ញុំទៅឈរអែបនឹងគល់ព្រីង និយាយខ្សឹបៗដាក់ត្រចៀកខ្ញុំ ៖

- តាមទិសផែនការអង្គការថ្នាក់លើដាក់ចុះមក គឺគេបើកឲ្យយុវជនយុវនារីប្ដេជ្ញា





(ពាក្យប្ដេជ្ញានេះ គឺបានសេចក្ដីថារៀបការ) ហើយអ្នកដែលត្រូវប្ដេជ្ញា ខាងស្រីទាល់តែមានអាយុម្ភៃប្រាំឆ្នាំឡើងទៅ បើម្ភៃប្រាំឆ្នាំចុះក្រោម មិនទាន់មានផែនការទេ។

ឮដូច្នោះ ខ្ញុំធ្លាក់ថ្លើមក្អុក ព្រោះខ្ញុំមានអាយុត្រូវតាមផែនការអង្គការកំណត់ឲ្យ។

- តើឥវ៉ាបានទេ? (ខ្ញុំសួរបញ្ជាក់ទៅមិត្តភក្តិ)

មិត្តខ្ញុំឆ្លើយតប ៖

- ដូចជាគ្មានសង្ឃឹមទេ!

មិត្តខ្ញុំឈប់មួយដង្ហើម ក៏បន្តសម្ដីតិចៗបន្ថែមទៀត ៖

- ខាងប្រុស ដូចជាមិនឮកំណត់អាយុថាប៉ុន្មានឡើយ។

មិត្តខ្ញុំប្រញាប់ដើរចេញទៅ ព្រោះការខ្សឹបខ្សៀវនេះសុទ្ធតែប្រព្រឹត្តទៅដោយលួចលាក់ជាទីបំផុត។ ពេលហូបបាយល្ងាច ខ្ញុំសង្កេតឃើញគេចែកបាយឲ្យមួយកូនចានកំភែល និងមានសម្លម្ជូរស្លឹកថ្នឹងមួយចាន ក្នុងនោះមានសាច់បួនដុំប៉ុនៗមេជើង តម្រូវមនុស្សបួននាក់។ ឃើញដូច្នេះ ខ្ញុំនឹកឃ្លានស្រក់ទឹកមាត់ច្រោក ហើយនឹកក្នុងចិត្តថា យី! គេជប់លៀងនរណាអីចេះ!

ទទួលពេលនោះ មិត្តខ្ញុំលួចប្រាប់ខ្ញុំ ៖

- អង្គការបំប៉នយុវជនយុវនារី ព្រោះជិតដល់ថ្ងៃប្ដេជ្ញាហើយ។ រំលងបានពីរបីថ្ងៃក្រោយមក នៅពេលសម្រាក ខ្ញុំលួចយកកញ្ចក់ដែលខ្ញុំរើសបានតាមផ្លូវមួយបំណែក មកឆ្លុះមុខឃើញថ្ពាល់ដែលកាលពីមុនផត ឥឡូវមានសាច់ពេញជាងពីពេលមុន។ ពេលយប់ ខ្ញុំតែងតែបន់ស្រន់នឹកគុណម៉ែគុណឪ សូមឲ្យខ្ញុំចៀសផុតពីការប្ដេជ្ញា ព្រោះខ្ញុំឥតមានបំណងចង់បានគ្រួសារសោះ។

ថ្ងៃប្ដេជ្ញា ជាថ្ងៃដែលខ្ញុំមិនរង់ចាំសោះ វាមកដល់យ៉ាងរហ័ស គឺថ្ងៃដប់ប្រាំបី ខែ

វិច្ឆិកា ឆ្នាំមួយពាន់ប្រាំបួនរយចិតសិបប្រាំពីរ (១៨-១១-១៩៧៧) យុវជនយុវនារីចំនួនហាសិបពីរគូត្រូវមានមុខនៅឯភូមិ។ ក្នុងបញ្ជីរាយនាមប្ដេជ្ញា មានឈ្មោះមិត្តនារី "ឃុន" គឺរូបខ្ញុំនេះឯង និងមិត្ត "ពិចិត្ត" ។ ព្រលឹមស្រាងៗឡើង ប្រធានក្រុមយកខោអាវខ្មៅមួយសម្រាប់ និងក្រមាថ្មីមួយមកឲ្យខ្ញុំ។ ខ្ញុំគេចទៅពួនយំនៅក្នុងព្រៃគុម្ពោត នឹកកម្សត់ខ្លួនពេក ព្រោះមានបងស្រីនឹងគេដែរ តែបងឃើនៅនឹងកន្ទេលគ្មានម៉ែគ្មានឪ គ្មានញាតិសន្ដាន ហើយម៉្យាងទៀត គ្មានបំណងប្រាថ្នានឹងប្ដេជ្ញានេះសោះ ជាពិសេសកម្លាំងពលំដែលមាននៅក្នុងខ្លួន ត្រូវទ្រុឌទ្រោមស្វិតរញមដូចបុប្ផាខ្វះទឹកសន្សើម តើមានចិត្តឯណានឹងត្រេកត្រអាល បើកូនកំលោះមិនដែលទាំងស្គាល់មុខផង... មិនដឹងជាមាននិស្ស័យ ឬក៏គ្មាននិស្ស័យ... ឱ! ហេតុអ្វីក៏ពួកវាមកបង្ខំចិត្តអញដូច្នេះទៅវិញ? ខ្ញុំនឹកគ្នាន់ក្នាញ់តែម្នាក់ឯង ក៏សម្រេចក្នុងចិត្តថាអញប្រហែលជាសុខចិត្តស្លាប់ជាជាងយកប្ដីបង្ខំចិត្តនេះហើយមើលទៅ។ នឹកឃើញដូច្នេះ ទឹកភ្នែកក៏ដណ្ដើមគ្នាហូរសស្រាក់ ខ្ញុំជូតរហូតទាល់តែជោកជាយក្រមាចេញពណ៌លាក់ដែលគេជ្រលក់ក្រហមដូចឈាម មកប្រឡាក់ថ្ពាល់ទាំងគូ និងដៃខ្ញុំ។

មិត្តខ្ញុំដើរតម្រង់មករកខ្ញុំ... ខ្ញុំខាំមាត់សង្កត់សេចក្ដីទុក្ខសោក ដែលកំពុងតែពុះកញ្ជ្រោលយ៉ាងចុកចាប់ពើតផ្សា... គេនិយាយតឿនខ្ញុំ ឲ្យប្រញាប់ប្រញាល់ឡើង ព្រោះយើងទាំងអស់គ្នាត្រូវស្រូតដំណើរទៅភូមិពីព្រលឹម ឯពិធីប្ដេជ្ញា គឺគេធ្វើពេលល្ងាចឯភូមិដែរ។ កូនក្រមុំទាំងហាសិបពីរនាក់ (៥២នាក់) មានទឹកមុខក្រៀមក្រំស្រពោន ចំណែកឯអ្នកដែលមិនទាន់ដល់អាយុប្ដេជ្ញា ត្រូវនៅធ្វើការដូចធម្មតា។

ដោយសារខែនេះជាខែកត្តិក បានជាធាតុអាកាសមិនសូវជាក្ដៅប៉ុន្មាន ទោះបីជាថ្ងៃជិតត្រង់ក៏ដោយ។ នៅពេលដែលយើងធ្វើដំណើរដល់ភូមិ មេក្រុមបានចង្អុល





បង្ហាញផ្ទះដែលខ្ញុំនឹងមកផ្សំដំណេក ខ្ញុំនឹកក្ដៅក្រហាយឥតឈប់ឈរ រួចស្អប់ដល់យុវជនដែលមកស្នើខ្ញុំ។

ពេលថ្ងៃប្រហែលជាម៉ោងពីរ នៅកន្លែងប្ដេជ្ញា គេចាក់ឧគ្ឃោសនសំព្វឮលាន់រំពងនូវបទចម្រៀង "កុមារបដិវត្តន៍[1]" និងបទចម្រៀងប៉ុន្មានបទទៀតចាក់សាចុះសាឡើងគួរឲ្យធុញទ្រាន់ពន់ពេក លក្ខណៈបែបនេះក៏ជាមធ្យោបាយសម្លាប់មួយ

*" កុមារបដិវត្តន៍ "*

១. យើងខ្ញុំកុមារ ស្រឡាញ់អង្គការ ឥតមានព្រំដែន
ដោយសារអង្គការ យើងខ្ញុំរស់រាន ជីវិតថ្កើងថ្កាន
រីករាយអស្ចារ្យ ។

២. មុនបដិវត្តន៍ កុមារក្រខ្សត់ រងទុក្ខវេទនា
រស់ដូចសត្វធាតុ គ្រាំគ្រាខ្លោចផ្សា អាក្សត់មោហា
គ្មាននឹកនាដល់ ។

៣. ស្បែកដណ្ដប់ឆ្អឹង ស្គមស្គាំងកំព្រឹង ហៅសែនកង្វល់
យប់ដេកនឹងដី ថ្ងៃឡើងខ្វាយខ្វល់ កាយកាកសំណល់
ដើរសុំទានគេ ។

៤. ឥឡូវយើងខ្ញុំ អង្គការឧត្ដម ឧបត្ថម្ភគ្រប់គ្រា
បំប៉នសុខភាព ជីវិតខ្លាំងក្លា ឲ្យរស់នៅជា
សមូហភាព ។

[1] ចម្រៀងនេះ ខ្ញុំបានស្រាវជ្រាវនៅថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៧ ពីឈ្មោះ អ៊ួន សុវណ្ណ មានមុខការជាមគ្គុទ្ទេសក៍ភាសាជប៉ុន។

| | | |
|---|---|---|
| ៥. មានស្លៀកមានពាក់ | លែងរងាញាក់ | លែងរស់ថោកទាប |
| រស្មីបដិវត្តន៍ | រស្មីស្មើភាព | សិទ្ធិសេរីភាព |
| | ថ្កើងថ្កានអស្ចារ្យ ។ | |
| ៦. ឱអស់អង្គការ | យើងខ្ញុំស្នេហា | ដ៏សែនជ្រាលជ្រៅ |
| យើងខ្ញុំប្ដេជ្ញា | ដើរតាមផ្លូវត្រង់ | ផ្លូវក្រហមឆ្នៅ |
| | អង្គការបវរ ។ | |
| ៧. ខិតខំរៀនសូត្រ | ឲ្យចេះដឹងស្ទាត់ | លេខនិងអក្សរ |
| ពលកម្មជំនាញ | សតិអារម្មណ៍ | ដើម្បីបន្ត |
| | ផនបដិវត្តន៍ ។ | |

បែបដែរ គឺវាធ្វើយ៉ាងណាឲ្យយើងសុញគំនិត ហើយទីបំផុតចិត្ត យើងក៏ស្រពោនក្រៀមក្រំទៅៗរហូតដល់ស្លាប់ដោយឯកឯង។ ដោយសារការគ្រប់គ្រងកាចសាហាវឃោរឃៅខ្លាំងពេក សូម្បីតែចម្រៀងដែលខ្ញុំចូលចិត្តក៏ដោយ ក៏ពេលនេះខ្ញុំបែរជាស្អប់ ហើយមិនចង់ស្ដាប់ទៅវិញ។

ឱ! ពុទ្ធោអើយ... ខ្ញុំមិនដឹងជាត្រូវដោះស្រាយដោយវិធីណាទេ បើខ្ញុំមិនដែលទាំងស្គាល់យុវជន ដែលត្រូវប្ដេជ្ញាជាមួយខ្ញុំផង សូម្បីតែឈ្មោះ ក៏ខ្ញុំពុំដែលឮដែរ ខ្ញុំកើតក្ដីបារម្ភឥតល្ហែ ហើយចេះតែនឹកទន្ទេញថា ម៉ែអើយជួយកូនស្រីផង... សូមឲ្យកូនរួចផុតពីជនពាលខ្មៅ។

គួរឲ្យចម្លែកណាស់... ក្នុងសម័យខ្មែរក្រហមកាន់កាប់នេះ គេមិនឲ្យគូប្ដេជ្ញាត្រូវចិត្តគ្នាទេ ផ្ទុយទៅវិញ គូប្ដេជ្ញាទាំងអស់នោះ សុទ្ធតែមានលក្ខណៈផ្ទុយគ្នាស្រឡះ





ឧទាហរណ៍ បើប្រុសល្អ ស្រីអាក្រក់ បើប្រុសចាស់ ស្រីក្មេង បើប្រុសទាប ស្រីខ្ពស់ បើគូប្ដេជ្ញាណាគ្មានទំនាស់ទេ នោះទើបគេចាត់ជាគូប្ដេជ្ញាគោរពវិន័យបាន គេថាដាច់ខាត។ ចំណែកឯរូបខ្ញុំក៏ចូលទៅក្នុងលក្ខណៈ ប្រុសក្មេង ស្រីចាស់ដែរ គឺបានសេចក្ដីថា គូខ្ញុំមានអាយុតិចជាងខ្ញុំប្រាំឆ្នាំ ដែលខ្ញុំពុំមានប្រាថ្នាដូច្នេះឡើយ។ រឿងនេះ មិនត្រឹមតែគូខ្ញុំមានអាយុតិចជាងខ្ញុំប៉ុណ្ណោះទេ ថែមទាំងខ្ញុំមិនដែលស្គាល់មុខមាត់គេដូចម្ដេចផង។ ពិធីប្រារព្ធធ្វើការប្ដេជ្ញា បានចាប់ផ្ដើមនៅវេលាម៉ោងពីររសៀល មុនដំបូង គណៈកម្មការភូមិបានឡើងប្រកាសកម្មវិធី ដែលមានទាំងអស់ប្រាំបីចំណុច គឺ :

១. ប្រកាសហេតុ

២. ប្រកាសគណៈអធិបតី

៣. គោរពភ្លេងជាតិ

៤. មតិណែនាំរបស់គណៈអធិបតី

៥. មតិតំណាងគូប្ដេជ្ញា

៦. មតិតំណាងមាតាបិតា

៧. ប្រកាសរំសាយ

៨. ហូបភោជនាហារកិត្តិយស

កម្មវិធីមួយចំណុចម្ដងៗបានកន្លងផុតទៅទាំងសោះកក្រោះ។ នៅទីបញ្ចប់ គឺចូលដល់កម្មវិធីទី៨ "ហូបភោជនាហារកិត្តិយស" ។ ថ្ងៃនេះ អង្គការធ្វើគុយទាវជប់លៀងគូស្រករថ្មី ប៉ុន្តែអង្គការមិនចម្អិនមួយចានម្ដងៗទេ គឺគេដាក់ទឹកដាក់សរសៃគុយទាវ ដាក់សាច់បីជាន់ចិញ្ច្រាំ រួចដាក់ស្ងោរជាមួយគ្នា លាយនឹងអំបិល

ឡមៗចំនួនពីរខ្ទះត្នោត។ រីឯសរសៃគុយទាវដាក់ស្មោរយូរទៅ ឡើងដាច់ៗផុយហ្មត់ខ្វល់ខាប់ទឹកដូចបបរទៅវិញ។ ខ្ញុំឃ្លានដែរ ប៉ុន្តែខ្ញុំហូបបានតែមួយចានសម្លធុនតូច ព្រោះខ្ញុំទ្រលាន់ខ្លាញ់ដែលមានចំនួនច្រើនលើសលប់ខ្លាំងពេក។ បន្ទាប់មកគេចែកនំទ្រាបខ្មៅមួយដុំម្នាក់។ ខ្ញុំឥតហូបនៅពេលនោះទេ លបលួចលាក់ទុកយកមកផ្ទះ ត្បិតក្នុងទ្រូងហាក់ដូចជាបេះដូងលោតខុសចង្វាក់ពីប្រក្រតី ព្រោះអ្វីដែលខ្ញុំនឹងត្រូវជួបគឺ យុវជនក្មេងម្នាក់។

លុះពិធីហូបភោជនាហារកិត្តិយសចប់រួចរាល់ហើយ ប្រធានភូមិបាននាំយើងមកកាន់ខ្ទមតូចដែលគេសង់ខ្ពស់ពីដី ដើម្បីឲ្យគ្រូស្រករស្នាក់នៅ។ ខ្ញុំឥតធ្វើដំណើរជាមួយគ្រូស្រករខ្ញុំទេ គឺខ្ញុំដើរជាមួយមិត្តនារីៗដូចគ្នា។ ផ្ទះដែលគេចង្អុលបង្ហាញខ្ញុំគឺជាផ្ទះក្បឿងចាស់ ទំនងដូចជាផ្ទះបាយរបស់គេពីដើម បើពុំនោះសោតទេប្រហែលជាជង្រុកស្រូវ ចំណែកឯទីវាលដែលគេទើបតែសង់ខ្ទមតូចៗ ប្រហែលជាកន្លែងគេសង់ផ្ទះធំ (តែឥឡូវត្រូវអង្គការរុះទៅហើយ) សេចក្តីសន្និដ្ឋានរបស់ខ្ញុំ ដូចជាសមហេតុសមផលម៉្យាងដែរ។ បន្ទាប់ពីប្រធានភូមិបានចង្អុលបង្ហាញហើយ ខ្ញុំក៏ដើរទៅឈរនៅក្រោមផ្ទះ ចំណែកឯមិត្តនារីខ្ញុំ គេក៏ដើរទៅកាន់ផ្ទះគេរៀងៗខ្លួន។ ខ្ញុំឈរនៅក្រោមផ្ទះ ដៃម្ខាងឱបសសរ ឯដៃម្ខាងទៀតទាញជាយក្រមាយកមកខាំជញ្ជឹងគិតចុះគិតឡើង... គំនិតទើលើការរត់គេចខ្លួន។ ប៉ុន្តែឧបមាថា បើខ្ញុំរត់គេចខ្លួន... តើខ្ញុំត្រូវទៅនៅជាមួយអ្នកណា... បើខ្លួនគ្មានឪពុកម្តាយ ឬញាតិសន្តានណាក្រៅពី... នៅក្នុងស្រុកនេះ មានតែបងស្រីម្នាក់... ឥឡូវបងឈឺនៅឯមន្ទីរពេទ្យស្រុក ... ហើយបើរត់ទៅជ្រកនឹងអ្នកដទៃ... ច្បាស់ជាគេមិនទទួលខ្ញុំទេ... ព្រោះគេខ្លាចស្លាប់ដែរ។ ខ្ញុំគិតមិនទាន់ដាច់ស្រេចថា នឹងត្រូវទៅផ្លូវណាផង... ស្រាប់តែខ្ញុំឃើញ





យុវជនម្នាក់ដើរមក។ គេមានមាឌធំក្រអាញ... សក់រួញអង្កាដី ដៃម្ខាងកាន់ចន្លុះបំភ្លឺផ្លូវ... ឯដៃម្ខាងទៀត កាន់រម្យូរកន្ទេលស្លឹកត្នោត ដោយបង្ហួសជំហានឡើងទៅលើផ្ទះតែម្តង។ ចំណែកខ្ញុំវិញ គ្រាន់តែក្រឡេកឃើញគេមួយភ្លែត ក៏គេចមុខបែរខ្នងរហូតទាល់តែគេឡើងផុតទៅ ទើបខ្ញុំងាកមុខមកវិញ។

តាមរនាបក្តារក្រាល ដែលកន្លែងខ្លះមានប្រឡោះប៉ុនៗម្រាមដៃ ធ្វើឲ្យខ្ញុំអាចសង្កេតឃើញពីសកម្មភាពរបស់យុវជនពិចិត្តនេះ។ ដំបូងគេយកចន្លុះទៅឈ្មួលបញ្ឆេះចង្កៀងប្រេងកាតតូចមួយ ដែលមាននៅលើធ្នើស្រាប់ ឲ្យឆេះឡើង រួចទើបពន្លត់ចន្លុះ ហើយបន្ទាប់មក គេក៏ក្រាលកន្ទេលស្លឹកត្នោតនោះទៅ។ តាមខ្ញុំស្មានប្រហែលជាគេឃើញខ្ញុំនៅក្រោមផ្ទះ ពេលគេកាន់ចន្លុះដើរចូលមក ទើបបានជាខ្ញុំឮគេហៅចំណេះខ្ញុំ ដោយសំឡេងស្រាលៗហើយថ្នមៗ ៖

- យុនឡើងមក។

ឮពាក្យមួយឃ្លានេះ ខ្ញុំភ្ញាក់ព្រើត ចង់ស្ទុះទៅមុខបន្តិច ចង់ថយក្រោយបន្តិចហើយនឹករំខានក្នុងចិត្តជាខ្លាំង។ មួយសន្ទុះក្រោយមក ដោយសារមិនឃើញខ្ញុំឡើងទៅលើផ្ទះតាមពាក្យអញ្ជើញរបស់គេ ខ្ញុំក៏ឮមាត់យុវជននិយាយហៅខ្ញុំសាជាថ្មីម្តងទៀត ៖

- យុនធ្វើដូច្នេះ ដូចជាមិនដឹងពីសភាពការណ៍ស្រុកទេស។

ឃ្លាយ៉ាងវែងនេះ ខ្ញុំក៏នៅតែឈរធ្មឹងដដែល ដោយឥតមាននឹកនាចង់ឡើងទៅលើផ្ទះបន្តិចណាសោះឡើយ គ្រាន់តែនឹក ៖

- អៃយ៉ា! គាត់នេះចេះនិយាយពាក្យពេជន៍ត្រឹមត្រូវផង។ សម្តីមួយឃ្លានេះហាក់ដូចជាបង្កប់នូវន័យគន្លឹះប្រាប់អញ។

កំពុងតែគិត ស្រាប់តែខ្ញុំឃើញស្រមោលខ្មៅ ស្ទុះភ្លែតចូលទៅសំងំពួនក្រោមខ្ទមមួយ ដែលមានចម្ងាយពីផ្ទះខ្ញុំប្រហែលជាដប់ម៉ែត្រ។ ខ្ញុំខ្លាចស្រមោលខ្មៅនេះណាស់ ដែលខ្ញុំឧប្បត្តិថា ជាស្រមោលបិសាច។ ខ្ញុំនឹកដល់មិត្តជាភ្លាម ព្រោះគេត្រូវបានស្រមោលបិសាចនេះនាំយកទៅសម្លាប់ទាំងយប់។

ខ្ញុំភ័យត្រជាក់ដៃត្រជាក់ជើង រួចស្ទុះសំដៅជណ្ដើរឡើងទៅលើផ្ទះ ទាំងព្រឺក្បាលសំពោង។ ទៅដល់កាំជណ្ដើរខាងលើត្រង់មាត់ទ្វារចូល ខ្ញុំឈរទ្រឹងសម្លឹងមើលទៅទិដ្ឋភាពនៅក្នុងផ្ទះ ខ្ញុំឃើញវាលល្វឹងមានតែកន្ទេលស្លឹកត្នោត ដែលយុវជននេះទើបនឹងក្រាល គ្មានបន្ទប់ គ្មានកន្លែងពួនឯណាគ្រាន់នឹងបានកក់ក្ដៅសោះ ឃើញមានតែសសរក្រឡោងមួយនៅចំកណ្ដាលផ្ទះ។ ខ្ញុំមានអាកប្បកិរិយាចង់ចុះមកដីវិញ ទើបយុវជននោះនិយាយលួងលោមខ្ញុំ ៖

- យុនគិតទៅណាវិញ... យប់ល្មមពេលសម្រាកហើយ។

ចំណែកឯចិត្តខ្ញុំវិញ... ចិត្តមួយខ្លាចស្រមោលបិសាច... ឯចិត្តមួយទៀត ខ្លាចបុរសក្មេងនេះ។ ខ្ញុំឈរអេះអុញស្នាក់ស្ទើរ រួចកាត់ចិត្តឆ្លើយទាំងកំបុតៗ ៖

- ខ្ញុំគិតរត់!

បុរសឧទាន ៖

- យុនរត់ទៅណា? ឈ្លបដឹង គេនឹងសម្លាប់យុន រួចសម្លាប់ខ្ញុំទៀត... ឱ! ម៉ែអើយ កូនមិនទាន់ចង់ស្លាប់ទេ។

ពាក្យប៉ុន្មានម៉ាត់នេះ ធ្វើឲ្យខ្ញុំនឹកខ្លោចចិត្ត ហើយគិតក្នុងចិត្ត ៖

- អីមែន! បើខ្លួនខ្ញុំស្លាប់ ស្លាប់តែម្នាក់ឯងចុះ កុំឲ្យយុវជននោះមកស្លាប់ជាមួយឯង ចោលម៉ែឪគេ។





ខ្ញុំឈរដកដង្ហើមធំនៅមាត់ទ្វារ ដែលឥតមានសន្លឹកបិទបាំង។ ពេលនោះ ភ្លៀងចាប់បង្អុរមក យុវជននិយាយ ៖

- ភ្លៀងអើយកុំរាំង!

ពាក្យមួយឃ្លានេះ ដូចបេះបិតទៅនឹងឃ្លាដែលបងស្រីខ្ញុំនិយាយ មុនពេលដែលខ្ញុំរៀបប្ដេជ្ញាមួយសប្ដាហ៍ ធ្វើឲ្យខ្ញុំនឹករឭកដល់បងស្រីកម្សត់ឥតភ្លេចសោះ។ ឮសម្ដីនេះ ក្នុងខ្លួនខ្ញុំហាក់ដូចជាមានអ្វីម៉្យាង ជំរុញខ្ញុំឲ្យងាកត្រឡប់ចូលមកក្នុងផ្ទះវិញដោយពុំមាននិយាយប្រកែក ឬតវ៉ាមួយម៉ាត់ឡើយ។ រួចហើយក៏ដើរមកកាន់កន្ទេលស្លឹកត្នោត ដែលមានទទឹងមួយម៉ែត្រហាសិប។ ខ្ញុំយកក្រមាមកមួលជារម្សូរប៉ុនកដៃ ហើយយករម្សូរក្រមានោះ ទៅលាតសន្ធឹងដាក់ខណ្ឌចំពាក់កណ្ដាលបណ្ដោយកន្ទេល ឯមាត់និយាយរអ៊ូៗល្មមតែឮគ្នាពីរនាក់ ៖

- អ្នកណាហ៊ានឆ្លងព្រំដែនអត់បានទេ ស្រែកឲ្យស្លាប់ទាំងអស់គ្នា។

ខ្ញុំនិយាយដូច្នេះ ព្រោះខ្ញុំក្ដាប់ចំណុចខ្សោយរបស់យុវជននេះបានហើយ ព្រោះគេបាននិយាយថា បើខ្ញុំស្លាប់ៗចុះ កុំឲ្យស្លាប់គេ ដូច្នេះយុវជននេះខ្លាចស្លាប់ ច្បាស់ជាពុំហ៊ានធ្វើអ្វីផ្ដេសផ្ដាសជាមួយខ្ញុំឡើយ។ ខ្ញុំយកសំពៀតមកកើយ ហើយហាក់ដូចជាកក់ក្ដៅនឹងខ្សែព្រំដែន ដែលខ្ញុំដាក់ខណ្ឌថាបានមាំទាំហើយ។ ខ្ញុំដេកបែរខ្នងឯក្នុងចិត្តចេះតែនឹកបារម្ភដល់យុវជនក្មេងនេះដែរ ប៉ុន្តែបើប្រៀបធៀបទៅនឹងពាងដោលឯទំនប់ទូលគ្រួស ឃើញមានលក្ខណៈប្រសើរជាងឆ្ងាយណាស់។ ជម្រកដែលខ្ញុំជ្រកជាមួយគូស្រករថ្មីនេះ ទូលាយល្វឹងល្វើយ គត់នឹងតំណក់ទឹកភ្លៀង... ម៉្យាងទៀត ថ្ងៃស្អែក និងថ្ងៃខានស្អែក គឺជាថ្ងៃដែលខ្ញុំបានសម្រាកពីការងារដ៏ធ្ងន់ធ្ងរព្រោះហើយភាពបារម្ភមានតែមួយ ឯភាពប្រសើរមានច្រើនជាង ធ្វើឲ្យខ្ញុំលង់លក់

ភ្លាមមួយរំពេច ដោយទុកឲ្យភ្លៀងនៅតែរលឹមស្រិចៗតាមការកំណត់នៃរដូវចុងឆ្នាំ។ មិនដឹងជាម៉ោងប៉ុន្មានទេ... ស្រាប់តែខ្ញុំភ្ញាក់ស្មុះក្រោកឡើង... ឃើញផ្ទៃបន្ទប់ទាំងមូលងងឹត... ប៉ុន្តែមិនងងឹតទាំងស្រុងនោះទេ ព្រោះទ្វារបង្អួចដែលគ្មានសន្ទះបិទបាំងបានជះពន្លឺព្រាលៗពីក្រៅចូលមក។ ខ្ញុំយកដៃស្ទាបខ្លួនប្រាណ ឃើញខ្ញុំនៅតែស្លៀកពាក់ដដែលដូចធម្មតា ឥតមានប្រែប្រួលខុសប្រក្រតីឡើយ។ ពិចិត្ត គូស្រករខ្ញុំក៏ភ្ញាក់ឡើងដែរ ហើយនិយាយខ្សឹបៗ ៖

- យុនភ័យឬ?

ខ្ញុំឥតឆ្លើយតប គ្រាន់តែនឹកជិនឬកគេតែម្នាក់ឯង។ ខ្ញុំឮសម្រិបជើងមនុស្សដើរកាត់តាមមុខផ្ទះខ្ញុំ... រួចខ្ញុំឮសំឡេងស្រីយំខ្សឹបខ្សួល ព្រមទាំងលាយសម្តីនិយាយអួលអាក់ ៖

- ម៉ែអើយ កូនលាហើយ! គ្រាន់តែកូនប្រកែកមិនព្រមផ្សំដំណេក ក៏មានទោសដល់ស្លាប់ដែរ!

ខ្ញុំឮមាត់ឈ្លបសង្សកគំរាម ៖

- បាត់មាត់!

សំឡេងសម្រិបជើងមនុស្សដើរសាត់ឆ្ងាយទៅៗ ពិចិត្តខិតមកជិតក្រមាដែលខ្ញុំដាក់ខណ្ឌ និយាយខ្សឹបៗ វាមិនពិបាកស្តាប់ទេ ព្រោះយើងនៅក្បែរខាងស្រាប់ ៖

- យប់មិញ បើយុនមិនសម្រាន្តលើកន្ទេលនេះទេ ច្បាស់ជា...។

យុវជនមិនបញ្ចប់ឃ្លា ប៉ុន្តែខ្ញុំក៏យល់ពីអ្វីដែលត្រូវបញ្ចប់ដែរ។ គេបន្តសម្តី ៖

- ពេលយុនសម្រាន្តលក់ ខ្ញុំងើបទៅពន្លត់ចង្កៀងដើម្បីជាសញ្ញាថា ខ្ញុំ និងយុនមិនខ្វែងគំនិតគ្នា។





ខ្ញុំឥតនិយាយស្តីអ្វីទាំងអស់ ទោះបីការនិយាយរបស់ពិចិត្តត្រូវចិត្តក្តី មិនត្រូវចិត្តក្តី ក៏ខ្ញុំនៅតែស្ងៀម រួចប្រះខ្លួនសម្រាន្តវិញទាំងរួញខ្លួនដូចដង្កូវដឹកខឿ គ្រាន់តែនឹកក្នុងចិត្ត ៖

- យី! ពួកបិសាចនេះ វាដើរយកការណ៍ពីគូស្រករថ្មី បើគូណាមិនចុះសម្រុងគ្នាទេ គឺវាអូសយកទៅសម្លាប់ដូចសត្វតិរច្ឆាន។

ខ្ញុំដេកដកដង្ហើមធំមួយសន្ទុះ ឮសម្រិបជើងមនុស្សដើរកាត់មុខផ្ទះខ្ញុំ។ ខ្ញុំក្រោកអង្គុយមើលឃើញគេសែងអង្រឹងពណ៌ខ្មៅ នៅខាងមុខមានមនុស្សដើរកាន់ចង្កៀង ទើបខ្ញុំដឹងថា គេសែងខ្មោចយកទៅកប់។

ខ្ញុំប្រះខ្លួនដេកជាថ្មីម្តងទៀត ប៉ុន្តែមិនដេកលក់ភ្លាមទេ ឯគំនិតគិតពិចារណាថា តើរូបខ្ញុំនេះកំពុងរស់នៅក្នុងឋានណា? ឋានមនុស្ស ឬឋានអវិចី បើឋានអវិចី ខ្ញុំពុំដែលឃើញផង ឃើញតែគេសរសេរប្រឌិតនៅក្នុងសៀវភៅ ឬមួយគេសម្តែងនៅក្នុងឈុតល្ខោន ឬក្នុងខ្សែភាពយន្ត រីឯការពិត ខ្ញុំពុំដែលជួបប្រទះឡើយ... ប៉ុន្តែពេលនេះ... ថ្ងៃនេះខ្ញុំកំពុងឋិតនៅក្នុងឋានដែលគេប្រឌិត... ហើយការប្រឌិតរបស់អ្នកនិពន្ធប្រែក្លាយទៅជាការពិតរបស់ខ្ញុំទៅវិញ។ ខ្ញុំយល់សប្តឬ? ទេ ខ្ញុំមិនយល់សប្តិទេ... គឺពិតជារូបខ្ញុំកំពុងតែផ្សំដំណេកជាមួយប្រុស ដែលខ្ញុំឥតមានចិត្តប៉ងប្រាថ្នាសោះ... ពួកវាចាប់យើងប្រជល់គ្នាដូចសត្វតិរច្ឆាន។

ភ្លឺហើយ ខ្ញុំនៅតែដេកបែរខ្នងដដែល។ ឈ្លបម្នាក់ឡើងមកលើផ្ទះខ្ញុំ ខ្ញុំធ្វើឫកជាដេកលក់ តែតាមការពិត ខ្ញុំស្អប់ពួកវា។ ចំណែកឯពិចិត្ត គេងើបឡើងទទួលគួរសម... ពេលនោះ ឈ្លបឡើងមកអង្គុយនៅមាត់ទ្វារ រួចសួរទៅពិចិត្តថា ៖

- មិត្តសុខសប្បាយទេ?

ពិចិត្តឆ្លើយតបភ្លាម ៖

- បាទបង សុខសប្បាយជាទេ។

សំណួរមួយ ចម្លើយមួយ ប៉ុន្តែបង្កប់នូវន័យពីរហើយស្រេច។ ឈ្លបមិននៅបង្អង់យូរ វាក៏ប្រញាប់ចុះទៅវិញ ព្រោះវាឃើញខ្ញុំនៅដេកនៅឡើយ ប្រហែលជាវានឹកថា ខ្ញុំអស់កម្លាំងខ្លាំងហើយ កាលពីយប់កន្លងទៅ។ ខ្ញុំក្រោកឡើង ខ្ញុំដូចជាអត់ខ្លាចមិត្តពិចិត្ត ព្រោះវេលាកន្លងទៅតែមួយយប់សោះ ខ្ញុំហាក់យល់បាននូវហេតុការណ៍ដ៏ច្រើន ហើយខ្ញុំមានការទុកចិត្តពិចិត្តថែមមួយកម្រិតទៀតផង។ ខ្ញុំលុបលាងមុខមាត់ហើយក៏ដើរទៅជិតពិចិត្ត រួចហុចនំទ្រាបមួយចំណែក ខ្លួនឯងទុកហូបមួយចំណែក ឯមួយចំណែកទៀត ទុកផ្ញើបងស្រីដែលសម្រាកនៅមន្ទីរពេទ្យ។ ពិចិត្តសម្លឹងមុខខ្ញុំយ៉ាងយូរ ទាល់តែខ្ញុំគេចមុខចេញមើលទៅភ្នំដំរីរមៀល ដែលលាតសន្ធឹងយ៉ាងវែងដូចសីមាខណ្ឌខេត្តតាកែវ និងខេត្តកំពត រួចពិចិត្តគ្រវីក្បាលប្រកែកព្រមទាំងនិយាយ ៖

- យុនទុកហូបខ្លួនឯងចុះ!

ខ្ញុំឆ្លើយដោយភ្នែកនៅតែសម្លឹងមើលទៅជួរភ្នំដដែល ៖

- នេះជារង្វាន់ដល់អ្នកដែលគោរពព្រំដែន។

ឮពាក្យខ្ញុំដូច្នេះ ពិចិត្តរបូតសំណើចលាន់ឃឹះ រួចឆ្លើយមកខ្ញុំទាំងមានលាយសំណើចតិចៗផង ៖

- មិនចាំបាច់រង្វាន់ទេ ឲ្យតែព្រមទំលាយព្រំដែន។

ពិចិត្តបញ្ចប់ពាក្យសឹងមិនទាន់ ស្រាប់តែខ្ញុំងាកទៅសំឡក់មុខគេដែលមិនទាន់ទាំងឈប់ញញឹម... លេចធ្មេញចង្កូមចំពើសស្រួចៗ... ស្រស់ណាស់... កំហឹងដែល





ខ្ញុំខឹងចាញ់ប្រៀបគេអម្បាញ់មិញ... បែរជានឹកចង់សើចតាមគេទៅវិញ។

ដោយសារភ្លឺហើយ យើងអាចនិយាយឆ្លើយឆ្លងគ្នាបានច្រើន មិនបារម្ភខ្លាចឈ្លបមកលួចស្តាប់... បើឃើញវា យើងដឹង រួចយើងឈប់និយាយគ្នាភ្លាម ប៉ុន្តែបើពេលយប់វិញ... យើងឥតហ៊ាននិយាយអ្វីក្រៅពីសំណួរ ឬចម្លើយចាំបាច់ឡើយ។

ព្រះអើយ... គ្រាន់តែរៀបចំខ្លួនប្រាណ ក៏ខ្ញុំលំបាកដែរ... ព្រោះតែផ្ទះនេះវាលល្វឹងពេក... ដើម្បីកុំឲ្យស្វាត់ពេក ក្រោយពីបានទាក់សម្តីគ្នាពីរបីម៉ាត់អម្បាញ់មិញមក ពិចិត្តផ្តើមសួរខ្ញុំ ៖

- យុនរៀបចំទៅណា?

ខ្ញុំឆ្លើយយ៉ាងស្រួល ហាក់ដូចជាពុំមានកើតហេតុអ្វីឡើយ ៖

- ព្រឹកនេះ ខ្ញុំត្រូវទៅមើលបងស្រីឯមន្ទីរពេទ្យស្រុក។

- យុនអនុញ្ញាតឲ្យខ្ញុំរួមដំណើរទេ?

ខ្ញុំដូចជារារែកក្នុងចិត្ត រួចឆ្លើយកំបុតៗឥតនិយាយចេញឈ្មោះ ៖

- តាមចិត្តចុះ។

ខ្ញុំសុំដូងខ្ចីប្រធានភូមិបានមួយ ទុកសម្រាប់យកទៅផ្ញើបងស្រី និងនំទ្រាបមួយកូនជុំ។

យើងធ្វើដំណើរដោយជើងចេញពីព្រលឹម។ ពិចិត្តកាន់ដូងខ្ចីមួយ ចំណែកឯខ្ញុំវិញពុំមានកាន់អ្វីទេ។ ខ្ញុំបានលួចចាត់ទុកពិចិត្តទុកដូចជាមិត្តម្នាក់ទៅចុះ។ ពេលធ្វើដំណើរ ខ្ញុំឆ្លៀតសួរពិចិត្តពីនេះពីនោះ រហូតខ្ញុំបានដឹងពីប្រវត្តិខ្លះៗរបស់គេ។ គេជាកូនឧត្តមសេនីយ ស្រុកកំណើតរបស់ឪពុកម្តាយគេនៅស្វាយរៀង... គេមានបងស្រីពីរនាក់ ដូច្នេះពិចិត្តជាកូនពៅដូចខ្ញុំដែរ ពិចិត្តពុំសួរខ្ញុំវិញទេ... ប្រហែលជាគេ

មិនចង់ដឹងអ្វីពីខ្ញុំឡើយ។ គេគ្រាន់តែដឹងថា " ខ្ញុំជាយុវនារី " តែប៉ុណ្ណោះ។ និយាយយូរៗ ខ្ញុំដូចជានឹករង្កៀសខ្លួនៗឯង... ឃើញតែខ្ញុំសួរគេអើយសួរ... ចំណែកឯគេវិញចាំតែឆ្លើយនឹងសំណួរខ្ញុំ ព្រមទាំងមានញញឹមអមចម្លើយផង។ នៅតាមបណ្តោយពីភូមិទៅមន្ទីរពេទ្យស្រុកស្ងាត់ច្រៀប... យូរៗមានឈ្លបជិះកង់មួយៗ ជួនកាលមានអ្នកដំណើរដើរបញ្ច្រាសខ្ញុំ ជួនកាលមានរទេះគោបរហួសទៅ ដូច្នេះគ្មានអ្វីមករំខានយើងទាំងពីរឡើយ។ ខ្ញុំមានអាកប្បកិរិយាដូចបក្សីបានរួចពីទ្រុង។ ឱ! ថ្ងៃនេះព្រះអាទិត្យអីក៏ភ្លឺស្រឡះម្ល៉េះ ខ្យល់អីក៏ត្រជាក់ម្ល៉េះ អាកាសអីក៏ប្រសើរម្ល៉េះ ខ្ញុំហាក់ភ្លេចខ្លួនថា នៅក្បែរខាងមានបុរសសង្ហាម្នាក់ ដែលមានទឹកមុខស្លូតបូតដើរប្រកិត។ ថ្វីត្បិតតែខ្ញុំមានអាយុលើសគេច្រើនក៏ដោយ ក៏មាឌដ៏តូចរបស់ខ្ញុំមើលទៅឃើញថាហាក់ដូចជានៅក្មេងដែរ។ ខ្ញុំឥតមានសង្ស័យ ឬក៏លួចបន្ទោសពិចិត្តទៀតទេ... ត្បិតកំហុសនេះ ជាកំហុសរបស់ពួកខ្មែរក្រហម ដែលវាចេះតែចាប់ផ្គូខ្ញុំនឹងគេតាមទំនើងចិត្តរបស់វា។ ខ្ញុំហាក់ដឹងថា ខ្ញុំបានទទួលសេចក្តីសប្បាយរីករាយដែរ ដែលធ្វើឲ្យផ្លូវពីភូមិមកមន្ទីរពេទ្យស្រុក ដូចជានៅជិតបង្កើយ។

មន្ទីរពេទ្យនេះឋិតនៅក្នុងបរិវេណវត្តត្រពាំងគល់។ មានអគារសង់អំពីឈើមានលំនាំដូចជាសាលារៀន អគារទាំងអស់មានចំនួនប្រាំខ្នងសង់ព័ទ្ធជុំវិញទីធ្លា ដោយបែរមុខទៅរកទីធ្លាដែលនៅខាងក្នុង។ នៅមុខអគារនីមួយៗមានកៅអីឈើវែងៗសម្រាប់អ្នកជំងឺអង្គុយលេង។ អគារដែលសង់តាមបណ្តោយដំណើរព្រះអាទិត្យ គេហៅថា "អគារបណ្តោយថ្ងៃ" អគារនេះមានពីរ គឺនៅខាងត្បូងមួយ ខាងជើងមួយ។ អគារពីរទៀតសង់នៅទិសខាងលិចសន្ទឹងពីជើងទៅត្បូង អគារនេះគេហៅថា "អគារទទឹងថ្ងៃ" អ្នកជំងឺណាដែលចូលអគារទទឹងថ្ងៃហើយ គឺសុទ្ធតែជាជំងឺធ្ងន់ធ្ងរ...





សេចក្តីសង្ឃឹមថាបានជា មានតិចតួចស្តួចស្តើងណាស់។ អ្នកជំងឺដែលសម្រាកនៅអគារបណ្តោយថ្ងៃខាងត្បូង ជាប្រភេទជំងឺស្រាល។ អ្នកសម្រាលកូន ឬអ្នកព្យាបាលរោគស្ត្រីសម្រាកនៅអគារបណ្តោយថ្ងៃខាងជើង។ ចំណែកឯអគារមួយទៀតសង់ទល់មុខនឹងអគារទទឹងថ្ងៃខាងលិច ជាអគារសម្រាប់ហូបបាយរួម។

ពិចិត្ត និងខ្ញុំដើរកាត់ទីធ្លា... អ្នកជំងឺប្រភេទស្រាលដែលងើបដើរបាន បានចេញមកអង្គុយនៅកៅអីឈើវែងខាងក្រៅ គេនាំគ្នាសម្លឹងមើលមកខ្ញុំ និងពិចិត្ត ពុំមែនជាក្រសែភ្នែកសរសើរយើងទាំងពីរនាក់ទេ ប៉ុន្តែជាក្រសែភ្នែកឃ្លាន ព្រោះឃើញពិចិត្តកាន់ដូងខ្ចីមួយនៅនឹងដៃ។ ខ្ញុំនឹកអាណិតណាស់ដែរ ប៉ុន្តែធ្វើដូចម្តេចហ្ន៎ បើជំនួនដ៏តិចតួចស្តួចស្តើងហួសនិស្ស័យនេះ ខ្ញុំបម្រុងយកទៅឲ្យបងស្រីសម្លាញ់របស់ខ្ញុំតែម្នាក់គត់ ដែលគាត់មានជំងឺដាបណាស់ទៅហើយ។ យើងទាំងពីរនាក់ដើរឆ្ពោះទៅអគារទិសខាងលិច... ទិសអស្តង្គត។ ចូលទៅដល់ភ្លាម ខ្ញុំមើលបងស្រីខ្ញុំសឹងពុំស្គាល់... ខ្ញុំគិតថា... ខ្ញុំឃ្លាតគាត់តែមួយអាទិត្យសោះ រូបរាងកាយរបស់បងខ្ញុំកាន់តែស្គមជាងថ្ងៃមុនឆ្ងាយណាស់។ កាលខ្ញុំជួបគាត់លើកមុន ក៏ខ្ញុំឃើញគាត់អង្គុយប្រងុក ឥឡូវខ្ញុំជួបគាត់លើកនេះទៀត ក៏គាត់នៅតែអង្គុយច្រងុក។ តាមខ្ញុំស្មានប្រហែលជាគាត់មិនបានសម្រាន្តលក់ទេ។ ខ្ញុំឃើញសក់ក្បាលគាត់កន្ទ្រើង ឯអាវដែលខ្ញុំពាក់ឲ្យមុនពេលខ្ញុំឃ្លាតទៅ ក៏នៅតែឃើញពាក់ដដែល។ ពុទ្ធោអើយ គេឥតផ្លាស់ឲ្យបងខ្ញុំទេ។ នៅពេលដែលខ្ញុំដើរចូលទៅជិតគ្រែ ក្លិនស្អុយជះកំសួលភាយៗមក... រុយមួយចំនួនកំពុងរោមលាមកផ្អើលឡើង ព្រោះឃើញមានមនុស្សដើរចូលទៅជិត... រួចវាហើរចូលទៅរោមវិញដដែល។ ខ្ញុំនិយាយមិនចេញ ព្រោះខ្ញុំអួលដើមក ឯទឹកភ្នែកដែលឡើងពេញប្រៀប ក៏ហៀរធ្លាក់ចុះមកកាត់ថ្ពាល់ទាំងសងខាង...

រួចធ្លាក់ទៅប៉ះគែមគ្រែ... ធ្លាក់បន្តខ្ចាយទៅដល់ដី... បន្តបន្ទាប់គ្នាហាក់ដូចជាភ្នែកទាំងគូរបស់ខ្ញុំ ជាប្រភពទឹកជ្រោះនៃទីកន្លែងណាមួយ។ ខ្ញុំយកដៃទាំងពីរទៅក្រសោបបងស្រី ខ្ញុំឮគាត់សួរខ្ញុំ ៖

- អ្នកណាហ្នឹង ?

បានសេចក្តីថា បងស្រីខ្ញុំស្រវាំងភ្នែកឥតស្គាល់ខ្ញុំទេ... ខ្ញុំខំប្រឹងនិយាយឈ្មោះខ្លួនឯងទាំងរអាក់រអួល ៖

- ខ្ញុំ... គឺ... យុន...។

ខ្ញុំសង្កេតឃើញបងខ្ញុំញញឹម ត្រេកអរទាំងលាយឡំដោយតំណក់ទឹកភ្នែកផង ហើយហាក់ដូចជាដឹងស្មារតី... ខំរំឭកឡើងវិញនូវអតីតកាលដ៏យូរលង់។ គាត់ងើបមុខឡើង ហើយសម្លឹងអ្នកដែលឈរនៅជិតគ្រែនោះដែរ... រួចខំរកនឹកសាជាថ្មី... ប៉ុន្តែចិញ្ចើមគាត់ជ្រួញ... គាត់រកនឹកមិនឃើញនូវរូបរាងមុខមាត់នេះទេ... គាត់មិនដែលស្គាល់ជននេះសោះ។ ឃើញដូច្នេះ ខ្ញុំក៏និយាយ ៖

- គេជាគ្រូសារខ្ញុំ... អង្គការទើបតែរៀបប្តេជ្ញាឲ្យ។

បងខ្ញុំខំញញឹមដាក់ប្អូនថ្លៃ រួចបន្លឺថា ៖

- ខំថែរក្សាគ្នាឲ្យបានសុខរហូតណា៎!

គាត់បញ្ចប់ឃ្លា... ព្រោះគាត់អស់កម្លាំងណាស់។ ខ្ញុំរត់ទៅរកផេះយកមកសម្អាតដូចខ្ញុំធ្វើកាលពីលើកមុន។ ចំណែកពិចិត្តកាប់ដូងចាក់ទឹកដាក់ត្រឡោក ដែលផ្កាប់នៅក្បាលដំណេក ហុចជូនទៅបង និងជួយកាន់ទ្របញ្ចុក... ខ្ញុំយកនំទ្រាបដែលខ្ញុំវេចខ្ចប់យ៉ាងស្អាតចេញពីហោប៉ៅបញ្ចុកបងទៀត។ ពិចិត្តលួចសម្លឹងមុខខ្ញុំ ដូចពេលខ្ញុំហុចនំទ្រាបទៅឲ្យគេ។ ខ្ញុំឃើញគេស្អាតណាស់ ស្រស់ណាស់ ភ្នែកទាំងគូរបស់





គេមុតចាក់ដល់បេះដូង ធ្វើឲ្យរញ្ជួយរង្គើ...រណ្តំក្នុងទ្រូងដ៏តូចរបស់ខ្ញុំ ដល់បេះដូងវារណ្តំខ្លាំងពេកទៅ ខ្ញុំដូចជានឹកខឹង... ដូចជានឹកស្អប់... ត្រឡប់ត្រឡិន... រួចនឹកអាណិតលាយឡំគ្នា។ ខ្ញុំនិងពិចិត្តលាបងស្រីត្រឡប់មកវិញ ព្រោះប្រញាប់ឲ្យទាន់ពេលថ្ងៃត្រង់ ម៉ោងល្ងាចនេះមានប្រជុំមួយយ៉ាងធំផង។

តាមដងផ្លូវ ខ្ញុំឥតនិយាយស្តីអ្វីសោះ... ព្រោះអារម្មណ៍ពេលឃ្លាតមក នៅតែជិតជាប់ភាពត្រមង់ត្រមោចដ៏សែនមហាកម្សត់ និងនឹកខ្លោចចិត្តអាណិតដល់បងដែលនៅម្នាក់ឯង។ ឱ! ព្រះអើយ មនុស្សដាបប៉ុណ្ណេះទៅហើយ ហេតុអ្វីក៏បានជាពួកវាមិនឲ្យមានអ្នកថែទាំបីបាច់ថ្នាក់ថ្នម គ្រាន់នឹងស្លាប់ទៅបិទភ្នែកជិត។ ខ្ញុំសង្កេតឃើញក្រសែភ្នែកអស់សង្ឃឹមរបស់បងស្រី ដែលសម្លឹងមើលមកខ្ញុំយ៉ាងយូរ ហាក់ចង់និយាយរៀបរាប់ពីការលាទៅដ៏សែនឆ្ងាយមួយ ឥតវិលត្រឡប់មកវិញបាន។ ខ្ញុំមានការចាប់អារម្មណ៍ដល់បងស្រី ដែលហូបទឹកដូង និងនំទ្រាបដែលខ្ញុំវេចយកទៅឲ្យ។ នឹកដល់ត្រង់នេះ ខ្ញុំដូចជាត្រេកអរឡើងវិញ ព្រោះបើតាមតែសម្តីគាត់ដែលនិយាយម៉ឺងម៉ាត់ថា គាត់មិនហូបអ្វីទាំងអស់... គាត់មិនត្រូវការរស់នៅតទៅទៀតទេ... ស្លាប់ចុះប្រសើរជាង ប៉ុន្តែខ្ញុំឆ្ងល់ណាស់... ព្រោះពេលខ្ញុំសម្អាតគ្រែ... ខ្ញុំទាំងបានយកបបររាវមួយចាន ដែលនៅចុងជើងមានរុយរោមអ៊ៃ យកទៅចាក់ចោលទៀតផង។ ដូច្នេះ តើការហូបទឹកដូង និងនំទ្រាប និងការមិនហូបបបរដែលនៅចុងជើងគ្រែនោះ មានន័យយ៉ាងណាដែរ? ឬមួយក៏បងស្រីខ្ញុំត្រេកអរពេកនឹងបានឃើញវត្តមានខ្ញុំ? ឬមួយក៏គាត់បានប្អូនថ្លៃប្រុស ដែលត្រកូលយើងគ្មានបងប្អូនប្រុសឯណាក្រៅពីលោកឪពុក?

ខ្ញុំនឹកសាចុះសាឡើង ស្លុងគំនិតតែនៅលើរូបបងស្រី ស្រាប់តែខ្ញុំជំពប់ជើងដូច

ជាគេលោតចម្ងាយឥតព្រាងទុកមួយ ដួលព្រួសទៅមុខ។ ពិចិត្តស្ទុះទៅបីត្រកងខ្ញុំ ដោយពុំបានសុំច្បាប់អនុញ្ញាតពីខ្ញុំជាមុនឡើយ។

ខ្ញុំភ្លេចឈឺ... ខ្ញុំភ័យ... រួចចេញកម្តៅពីខ្លួនភាយៗដូចបម្រុងនឹងគ្រុន។ ខ្ញុំហាក់ដូចជាដឹងថា បានកក់ក្តៅបន្តិចដែរ... ប៉ុន្តែខ្ញុំនឹកខ្មាសខ្លាំងពេក ក៏លួចក្តិចពិចិត្តទាល់តែគេលែងខ្ញុំ... ហើយគេក៏មានអាកប្បកិរិយាដូចជាភ្ញាក់...រួចដាក់ខ្ញុំចុះ។ សាច់ដែលប៉ះហើយរូតនឹងថ្មល់ក្រាលក្រួសក្រហម មានដាច់ចេញឈាមព្រិចៗ ធ្វើឲ្យខ្ញុំឈឺចាប់... ខ្ញុំមិនទាន់បាត់ចុកចាប់នៅឡើយទេ... នៅអង្គុយលើភ្លឺក្បែរថ្មល់... ព្រោះពេលដែលពិចិត្តដាក់ខ្ញុំចុះ ខ្ញុំក៏អង្គុយនៅទីនោះតែម្តង។ ពិចិត្តទាញជាយក្រមាជូតឈាម រួចយកស្មៅចិញ្ចៀនមកទំពាបិទចំកន្លែងដែលមានរបួស។ ខ្ញុំឥតប្រកែកទាំងកាយវិការទាំងសម្តី ដោយទុកឱកាសឲ្យគេបិទថ្នាំឲ្យខ្ញុំតាមអំពើចិត្តរបស់គេ។ ពិចិត្តសួរខ្ញុំ ៖

- យុនអាចដើរបានទេ ?

ខ្ញុំគ្រវីក្បាល រួចឆ្លើយតបទាំងប្រថុយប្រថាន ៖

- ទាល់តែមានជំនួយ!

ពិចិត្តឆ្លើយរបៀបរួសរាន់ ៖

- បើអីចឹងទៅ កុំឲ្យយូរ។

ខ្ញុំខំប្រឹងដើបឈរដោយមានពិចិត្តជាអ្នកជួយ... ហើយក៏បោះជំហានបន្តិចៗដូចជាកូនក្មេងទើបនឹងហាត់ដើរដំបូង។ សំពត់ និងអាវដែលកកិតនឹងដី ខ្ញុំឃើញសឹកហើយដាច់បន្តិចៗផង។

ពេលល្ងាចយើងជួបជុំគ្នានៅផាងបាយរួម ដើម្បីស្តាប់សេចក្តីថ្លែងការណ៍របស់





អង្គការ។ ខ្ញុំសង្កេតឃើញជាទូទៅ មិត្តភក្តិរបស់ខ្ញុំមានទឹកមុខស្រពាប់ស្រពោនតាមខ្ញុំស្មាន ប្រហែលជាមិនចុះសម្រុងនឹងគូស្រករថ្មីទេដឹង ? មិត្តខ្លះគ្រាន់តែឃើញមុខខ្ញុំ ស្រាប់តែរលីងរលោង... ចំណែកខ្ញុំវិញក៏ដូចជារន្ធត់ញាប់ញ័រចំប្រប់លាយទឹ្យទៅដោយក្តីមេត្តាដែរ។

មានមិត្តខ្លះឱនមកខ្សឹបប្រាប់ខ្ញុំថា ៖

- យប់មិញ មានគ្នាយើងខ្លះស្លាប់ដោយហាល់នឹងការហូបច្រើនហួសកំណត់ពេក និងមានមួយចំនួនទៀតត្រូវពួកវាយកទៅសម្លាប់ ព្រោះតែមិនព្រមផ្សំដំណេក។

ឮមិត្តភក្តិនិយាយដល់ត្រង់នេះ ខ្ញុំនឹកដល់ខ្សែព្រំដែន... ចុះបើពួកវាដឹង ខ្ញុំប្រហែលជាត្រូវគេយកទៅសម្លាប់ហើយមើលទៅ។ ឱ! ពិចិត្តអើយ នៅសល់តែពីរយប់ទៀតទេ ដែលពួកវាត្រូវយកការណ៍ឲ្យអស់ពីគូស្រករថ្មី។ ក្នុងពីរយប់នោះ តើយប់ណាមួយដែលវាមកយកការណ៍ពីគ្រួសារខ្ញុំ... ហើយខ្ញុំនៅតែស្ងាត់ឈឹងដូច្នេះឬ? ឬមួយក៏ទៅនិយាយអង្វរពិចិត្ត... តើគេព្រមតាមគំនិតខ្ញុំដែរ... បើគេជាប្រុស... ខ្ញុំជាស្រី។ អ្នកម្តាយខ្ញុំតែងតែប្រៀនប្រដៅខ្ញុំ កាលខ្ញុំនៅជាមួយគាត់ៗ មានប្រសាសន៍ថា ស្រី និងប្រុស ចាស់លោកហាមមិនឲ្យនៅជិតគ្នាតែពីរនាក់ទេ... ខ្លាចមោហ៍វាបាំង... ផញ្ចាំងវាបិទ... ហើយសៀវភៅទាំងឡាយក៏លើកឡើងពីបញ្ហាស្រី និងប្រុសនេះដែរ ថាមានកម្លាំងស្រូប... ជួនកាលប្រុសឥតមានស្រឡាញ់ស្រី ទុកដូចជាភរិយាទេ... ប៉ុន្តែដោយសារតណ្ហាប្រុសបានខ្លួនប្រាណស្រីហើយ គេក៏បោះបង់ចោលស្រីទៅ ព្រោះគេជាមាសទឹកដប់ ឯស្រីវិញប្រៀបដូចជាក្រណាត់ស បើវាប្រឡាក់ហើយ មិនងាយនឹងបោកគក់ឲ្យជ្រះដូចដើមបានវិញទេ។ ដូច្នេះមុននឹងរៀបការ ត្រូវតែពិនិត្យឲ្យបានហ្មត់ចត់គ្រប់ជ្រុងជ្រោយ ដើម្បីកុំឲ្យមានការសោកស្តាយទៅថ្ងៃ

ក្រោយ។ តែពេលនេះ ម៉ែអើយ! ពួកវាមិនឲ្យកូនជ្រើសរើសតាមទំនើងចិត្តកូនប្រាថ្នាទេ។ កូនបារម្ភដល់វាសនាអនាគតរបស់កូនណាស់។ ខ្ញុំគិតច្រើនណាស់ រហូតទាល់តែខ្ញុំមិនបានដឹងថា ប្រធានចូលមកតាំងពីពេលណាផង ស្រាប់តែខ្ញុំឮសូរគេទះដៃប្រាវឡើង... ខ្ញុំក៏ភ្ញាក់ពីការស្លុងគំនិត រួចក៏ភ្ញាក់ទះដៃនឹងគេដែរ។ ប្រធានឡើងនិយាយណែនាំ ៖

- ការគោរពអង្គការវិន័យ គឺជាទិសដៅ និងជាភារកិច្ចសំខាន់ណាស់សម្រាប់អង្គការយើង... ហើយការប្ដេជ្ញានេះ ក៏ជាទិសដៅកសាងជាតិចម្បងដែរ... អង្គការសូមសរសើរសមមិត្តនារីឃុន និងសមមិត្តពិចិត្ត ថាជាគូប្ដេជ្ញាគំរូ...។

គ្រាន់តែប្រធាននិយាយចប់ ស្នូរទះដៃលាន់រំពងឡើង។ ខ្ញុំភ័យប្រហោងពោះធ្លុង... ខ្ញុំខ្មាសគេសឹងដាច់ខ្យល់... ខ្ញុំបែកញើសស្រាក់ៗ... ព្រោះការពិត ខ្ញុំឥតដូចប្រធានលើកឡើងក្នុងអង្គប្រជុំនេះទេ។ គេចោលភ្នែកទាំងគូៗ សម្លឹងមើលមកខ្ញុំគ្រប់ៗគ្នា។

ខ្ញុំនឹកខ្មាសពិចិត្តស្រៀវអស់ទាំងខ្លួន... រួចនឹកឃើញខ្ញុំឈរឱបសសរនៅក្រោមផ្ទះ... បៀមជាយក្រមា... ពិចិត្តប្រហែលជារិះគន់ខ្ញុំខ្លាំងជាងគេទាំងអស់ហើយមើលទៅ។

ពេលប្រជុំចប់ ដល់ម៉ោងហូបបាយល្ងាចល្មម ខ្ញុំលេបបាយបានតែពីរបីម៉ាត់គត់... ចំណែកឯបាយដែលនៅសល់ ខ្ញុំលួចចាក់ដាក់ហោប៉ៅអាវ រួចគ្រលំក្រមាពីក្រៅដើម្បីបិទបាំងកុំឲ្យគេមើលឃើញ។ ខ្ញុំនឹកចម្លែកក្នុងខ្លួន... កាលពីមុនខ្ញុំស្រឡាញ់ពេលយប់ណាស់ ព្រោះពេលយប់ ខ្ញុំបាននឹកស្រមៃទៅម្ដាយឪពុក បងប្អូន តែពេលនេះខ្ញុំខ្លាចពេលយប់... ខ្ញុំមិនចង់ឲ្យដល់ពេលយប់ទេ... ព្រោះខ្ញុំខ្លាចកន្ទេលស្លឹក





ត្នោត។ ខ្ញុំដើរមកផ្ទះជាមួយអ្នកជិតខាងមានវ័យចំណាស់ម្នាក់ឈ្មោះ " ម៉ៅ " គាត់ជាអ្នកថ្មីដូចខ្ញុំដែរ។ មុនខ្ញុំប្ដេជ្ញាមួយថ្ងៃ អង្គការបានយកប្ដីមីងម៉ៅទៅរៀនសូត្រ ព្រោះតែរឿងប្ដីគាត់ធ្វើឲ្យបាក់ដងនង្គ័ល។ ក្រឡេកឃើញខ្ញុំ មីងម៉ៅប្រញាប់និយាយ ៖

- មីអូនឯង កុំទទឹងនឹងគេឲ្យសោះណាំ... អស់រយៈពេលបីថ្ងៃហើយ ពូឯង ( ពូឯងនេះ គឺប្ដីរបស់គាត់ ) ឥតឃើញវិលមកវិញទេ... មីងទន្ទឹងរង់ចាំមើលផ្លូវគាត់ផ្សាភ្នែកហើយ...

មីងម៉ៅឈប់ដកដង្ហើមបន្តិច រួចបន្តវាចាទៀត ៖

- មីងបានឮគេប្រកាសថា ឯងជាគូប្ដេជ្ញាគំរូ... ឯងចុះសម្រុងគ្នា... មិនប្រឆាំងគ្នា... មីងជួយត្រេកអរណាស់...

ខ្ញុំឆ្លើយកាត់សម្ដីមីងម៉ៅ ៖

- មីង... ខ្ញុំឥតស្រឡាញ់គ្រួសារខ្ញុំទេ។

មីងម៉ៅមិនដឹងជាគាត់យល់យ៉ាងណា បានជាគាត់ឆ្លើយតបមកខ្ញុំវិញ ៖

- បន្តិចទៀតឯងគង់នឹងនឹកគេ... ស្រឡាញ់គេ... ហើយទន្ទឹងរង់ចាំមើលផ្លូវគេ... កាលណាគេឃ្លាតទៅ... ដូចជារូបមីងអីចឹងណាំក្មួយ។

ដល់ផ្ទះមីងម៉ៅហើយ... គាត់បែកទៅ... ខ្ញុំក៏បង្ហួសដំណើរដោយស្ងៀមស្ងាត់តែម្នាក់ឯង។ មកដល់ផ្ទះ... ខ្ញុំឆ្លៀតបោសសម្អាតក្រោមផ្ទះ និងបរិវេណ រួចឡើងមកបោសសម្អាតលើផ្ទះទៀត។ ខ្ញុំឥតឃើញពិចិត្តទេ... ក្នុងខ្លួនខ្ញុំដូចជាធូរបន្តិចដែរ ហើយចេះតែនឹកដល់សម្ដីមីងម៉ៅថា នឹកគេ... ស្រឡាញ់គេ... ទេ ដូចជាមិនត្រូវសោះសម្ដីនេះ... បើថានឹកម៉ែ... ស្រឡាញ់ម៉ែ ដូចជាត្រូវជាង។

ខ្ញុំដើរទៅរកមុជទឹកនៅត្រពាំងក្បែរផ្ទះ ស្រាប់តែខ្ញុំឃើញពិចិត្តពីចម្ងាយ ខ្ញុំគេច